**BMI0108**

# សម្ភាសន៍ជាមួយឈ្មោះ យឹម វើយ ភេទប្រុស អាយុ៦០ឆ្នាំ
# មុខងារនៅសម័យខ្មែរក្រហមៈ ប្រធានកងយុវជន (ក្តាប់១០០នាក់)
# សព្វថ្ងៃរស់នៅភូមិស្វាយ ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ
# ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០
# សម្ភាសន៍ដោយៈ សោម ប៊ុនថន
# ០១:២៦:៣២
# ២៦ទំព័រ

ប៊ុនថន : ដំបូងខ្ញុំចង់សួរឈ្មោះពូ ពូឈ្មោះអីដែរ?

វើយ : បាទ! ខ្ញុំឈ្មោះ យឹម វើយ ។

ប៊ុនថន : ពូអាយុប៉ុន្មាន?

វើយ : អឺ! អាយុ៦០ ។

ប៊ុនថន : ពូភូមិ?

វើយ : ភូមិកំណើតនៅភូមិស្វាយ ។

ប៊ុនថន : ឃុំ?

វើយ : ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។ អឺ!ពីដើមខេត្ត អូ!នែក បាត់ដំបង ។ បាទ! តែមកដល់ឥឡូវចូលមកដល់ខេត្តបន្ទាយមានជ័យវិញ ។

ប៊ុនថន : គេបំបែកឆ្នាំណាដែរ?

វើយ : បាទ! គេបំបែកខេត្តនៅឆ្នាំ ក្រោយយើងនេះឯង ក្រោយ ។

ប៊ុនថន : សមាហរណកម្ម?

វើយ : បាទ!ក្រោយនឹងឯង ។

ប៊ុនថន : ផ្តាច់ខ្លួន?

វើយ : ក្រោយផ្តាច់ខ្លួនទៅទៀត បានគេបំបែកទៅជាខេត្តឧត្តរមានជ័យ(បន្ទាយមានជ័យ) ។ បើពីសាធារណរដ្ឋមិញវិញនោះ គេថាខេត្តបាត់ដំបង តែអនុខេត្តបន្ទាយឆ្មារ ។

ប៊ុនថន : ខេត្តបន្ទាយឆ្មារ?

វើយ : អនុខេត្តបន្ទាយឆ្មា ។

ប៊ុនថន : អនុខេត្តម៉េចទៅ?

វឿយ : អឺ! ពីដើមខេត្តនឹងយើងហៅថា ទន្ទឹមនឹងចេញជាខេត្ត មានអនុខេត្ត ខេត្តអនុខេត្ត ។

ប៊ុនថន : ចឹងបន្ទាយឆ្មារនឹងជាអនុខេត្ត?

វឿយ : អនុខេត្តបន្ទាយឆ្មារ ។

ប៊ុនថន : ហើយលោកពូរៀនដល់ថ្នាក់ទីប៉ុន្មាន?

វឿយ : រៀនថាសេដ្ឋកិច្ច យកទៅរៀនសូត្រ ។

ប៊ុនថន : ពូរៀនដសូត្រដល់ថ្នាក់ណាដែរ?

វឿយ : ខ្ញុំរៀនសូត្រដល់ថ្នាក់ទី៦ ។

ប៊ុនថន : ទី៦ សង្គមចាស់ ។

វឿយ : អឺ!

ប៊ុនថន : បាទ! ចឹងលោកពូរៀនបានច្រើនៗដែរ?

វឿយ : មិនបានច្រើនប៉ុន្មានទេ ។

ប៊ុនថន : ហើយពូចូលរៀនៗនៅឆ្នាំណាដែរ ហើយរៀននៅសាលាណា?

វឿយ : ខ្ញុំកាលចូលរៀនហ្នឹង ដូចជាថាជំនាន់ខ្ញុំមិនបានទេ ។ តែរៀននៅសាលាបឋមសិក្សាភូមិស្វាយ អឺ!សាលាបឋមសិក្សាថ្មពួក បាទ! ភូមិស្វាយមិនទាន់មានសាលាទេ ។

ប៊ុនថន : ចុះ ហើយសម័យរដ្ឋប្រហារពូនៅរៀនទេ ឬក៏ឈប់រៀនហើយ?

វឿយ : អឺ! សម័យលន់ លន់?

ប៊ុនថន : បាទ!

វឿយ : អឺ! នៅក្នុងសម័យនោះជំនាន់នោះខ្ញុំនៅរៀននៅឡើយទេ នៅរៀនមើលរហូតដល់ថ្ងៃខែដែលប្រែប្រួល ៣ឆ្នាំ ៨ខែ ចាប់ផ្ដើមចប់ ខ្ញុំក៏ចាប់រៀន ។

ប៊ុនថន : ចឹងពូរៀនរហូតដល់សម័យខ្មែរក្រហមចូលមក?

វឿយ : បាទ!

ប៊ុនថន : ប៉ុនមុននឹងដូចពូរៀនហ្នឹង ពេលនឹងមានខ្មែរក្រហមចូលមកភូមិឥឡូវ?

វឿយ : បាទ! មិនដែលមានទេ ។ នៅថ្មពួកនេះមិនដែលមានខ្មែរក្រហមចូលមកជិតដែនដីស្រុកថ្មពួក នេះមិនដែលមាន ។ អូ! ស្រុកមាននៅឆ្ងាយ តែក្នុងឃុំថ្មពួកមិនដែលមានខ្មែរក្រហមចូល មកជិតទេ មិនដែលមានអ្នកណាមួយដែលស្គាល់នេះជាខ្មែរក្រហម នេះជារយៈខ្មែរក្រហម អត់មានទេ ។

ប៊ុនថន : ចឹងនៅឆ្ងាយនឹង ភូមិអីខ្លះ?

វើយ ៖ នៅឆ្ងាយនឹង នៅទីមដូចថាភូមិផ្ដាំៗមាន ដូចជា........ស្រែរបស់ខ្មែរក្រហមនៅខាងភ្នំអានឹងមានរបស់គាត់ ។ បើថាឲ្យឈានពីនោះមក មិនទាន់មានមិនដែលជួប ហើយក៏មិនដែលស្គាល់ថាផ្ទះណាមួយដែលជាខ្មែរក្រហម ហើយរយៈក៏គ្មានមិនដែលមាន ។ មានតែទាហានអឺ!សម័យនោះគេហៅទាហានឃុំ គឺទាហានលោកច្រើន ដែលថែរក្សានៅទឹកដីនឹង ។

ប៊ុនថន ៖ ទាហានឃុំៗ?

វើយ ៖ ទាហានឃុំកាលសម័យនោះគេជ្រើសរើសជាទាហានឃុំ ទាហានឃុំនឹងគឺថាចំនុះម៉ាស្រុកថ្ពួកនេះ គឺមានទាហាន ម៉ាមេបញ្ជាការមួយលោកច្រើន ដែលគាត់ទទួលខុសត្រូវ ។ ហើយ ក្នុងនាទីនោះ គឺថាគាត់ការពារដីត្រង់នេះ មិនដែលមានជាតិខ្មែរក្រហមណាចូលមកជិតបាន ។

ប៊ុនថន ៖ ចឹងការរស់នៅរៀនសូត្ររបស់ពូនឹង អត់មានធម្មតា?

វើយ ៖ នៅធម្មតា អត់មានច្រលូកច្របល់អី ឬក៏នយោបាយអីនិយាយពីខ្មែរក្រហមអត់មាននេះកាលដែលខ្ញុំរៀនសូត្រនឹង មិនដែលមាន អត់មានជួបប្រទះស្គាល់គេទេ ។

ប៊ុនថន ៖ ចឹងរហូតដល់ខ្មែរក្រហមចូលមកនឹង តើមានការផ្លាស់ប្ដូរអីយ៉ាងម៉េច?

វើយ ៖ អឺ! វាធម្មតាការសិក្សារហូតដល់៣ឆ្នាំ ៨ខែ គឺពួកខ្មែរក្រហមបានប្រកាសថាជ័យជំនះឈ្នះលើគេហើយ ។ នៅក្នុងនោះពួកខ្ញុំថាជាក្មេងមួយដែលដឹងក្ដីហើយ ដឹងច្បាស់ហើយ គឺបានទៅនៅការពារ គេឲ្យទៅនៅការពារដូចថាពេលយប់ចឹងទៅៗយាម ឧទាហរណ៍ថាដូចសព្វថ្ងៃហៅថា ខ្ញុំស្មើនឹងឈ្លបអានឹងគ្រាន់តែម៉ាយប់គេត្រូវយកប៉ុន្មាននាក់ទៅជួយការពារហើយយើងការពារទៅគេប្រកាសឲ្យចប់ៗ ។ ចប់ស្រាប់តែឃើញគេធ្វើដំណើរមក... ជាសំលៀកបំពាក់ខ្មៅ ចេញមកមានអាវុធមានអីមក ។ គេថាអូ! កងទ័ពអឺ!កងទ័ពបដិវត្តៗបានចូលមកដល់ហើយ ។ យើងក៏នាំគ្នាទាំងអស់គ្នាថាទៅជ័យយោ កងទ័ពបដិវត្តទៅ ។ មិនដែលមានរយៈមុន ឬស្គាល់មុនមិនដែលមានទេ ។

ប៊ុនថន ៖ បាទ! ចូលមដល់ភ្លាមឃើញភ្លាម?

វើយ ៖ ឃើញភ្លាម ដល់ឃើញភ្លាម ហើយគេក៏អរជយោ យើងក៏ជយោនឹងគេទៅ យើងពលធ្វើម៉េច បើមិនជ័យ ។

ប៊ុនថន ៖ ចុះលោកពូមានជម្លៀសទៅភូមិអីផ្សេងទេ?

វើយ ៖ បាទ! ទេ អត់មានទេ នៅតែក្នុងមូលដ្ឋាន ភូមិស្វាយនេះ មានចល័តៗនឹងគឺថាទៅវិញទៅមកដូចថាទៅធ្វើការនៅក្នុងស្រុក អាងត្រពាំងថ្មយើង ។

ប៊ុនថន ៖ បាទ! ពូធ្លាប់ទៅដែរ?

វើយ ៖ បាទ! ចល័តនឹងធ្លាប់ទៅ ដូចថាមានគេចល័ត ។

ប៊ុនថន ៖ ចុះពូចូលមកដល់ភ្ជាមហ្នឹងមានការផ្លាស់ប្តូរអីទេ រដ្ឋអំណាចឃុំ ប្រធានភូមិ ប្រធានឃុំ?

វើយ ៖ អត់ទេ ក្នុងពេលដែលអឺ! រដ្ឋកម្ពុជាចូលមកដល់ ។

ប៊ុនថន ៖ ខ្មែរក្រហមចូល ខ្មែរក្រហម?

វើយ ៖ ខ្មែរក្រហមចូលមកដល់ ក្នុងពេលនោះបានជ្រើសរើស អឺ!ជាមិនមែនជាប្រធានទេ គឺជ្រើសរើសហៅថាជាអ្នកសង្កេតការណ៍ គឺសម័យនោះហៅថាឈ្លបៗ សង្កេតការណ៍ ។ បាទ! ជ្រើសរើសនោះ ត្រង់ថានៅក្នុងស្រុកភូមិនេះមានអ្វីខ្លះ ក៏អឺ!នាំដើររក ដើរមើលថា ផ្ទះនេះមានស្អីខ្លះៗ ។ ក្រោយមកទៀត ក្នុងរយៈពេលអឺ! ៦ខែមិបានម៉ាឆ្នាំទេ ខ្ញុំក៏បាន ចេញទៅកងចល័ត ។

ប៊ុនថន ៖ បាទ! ពូបានចូលទេ អីសង្កេតការណ៍?

វើយ ៖ ដើរដំបូងខ្ញុំបានចូលសង្កេតការណ៍ តែក្នុងរយៈពេលមិនជាយូរប៉ុន្មានទេ ប្រហែលជាថា៦ខែចុះ មិនបានម៉ាឆ្នាំទេ ខ្ញុំក៏ចាប់ចេញដើរចល័ត ចូលទៅកងចល័តវិញ ។

ប៊ុនថន ៖ ម៉េចៗ បានពូផ្លាស់ចេញ?

វើយ ៖ ទេ! អានឹងវាជារឿងមួយរបស់អ្នកដឹកនាំនៅក្នុងសង្គមនឹង ។

ប៊ុនថន ៖ ពីណាអ្នកជ្រើសរើស?

វើយ ៖ បាទ! ចៅសង្កាត់របស់គេ ។

ប៊ុនថន ៖ ចៅសង្កាត់នឹងជ្រើសរើសថ្មីដែរ ឬមួយក៏ចាស់?

វើយ ៖ ចៅសង្កាត់នឹងចាស់ អត់មែនចៅសង្កាត់ថ្មីទេ អានឹងគេហៅពួកមេភូមិថ្មី ចៅសង្កាត់នឹងក៏ថ្មី

ប៊ុនថន ៖ បាទ! ជ្រើសរើសថ្មីទាំងអស់?

វើយ ៖ បាទ! ជ្រើសរើសថ្មីទាំងអស់ ។

ប៊ុនថន ៖ ប៉ុនគាត់ស្រុកកំណើតនៅណា?

វើយ ៖ ស្រុកកំណើតនៅស្រុកថ្មពួកយើងនេះទាំងអស់ ។ បាទ! សូម្បីតែមេភូមិក៏នៅភូមិស្វាយនេះ តែបើចៅសង្កាត់នៅថ្មពួក មិនមែនយកមកពីណាទេ ។ បានក្រោយមកក្នុងរយៈពេលមួយ ឆ្នាំ ដូរចៅសង្កាត់ទាំងអស់ ។

ប៊ុនថន ៖ កាលនឹងពូទៅកងចល័តនៅ?

វើយ ៈ បង្កើតជាសហករណ៍ ។ បាទ!បង្កើតជាសហករណ៍ ដូរពីសន្កាត់ៗបាត់អស់ ចូលជាសហករណ៍ ។ ចឹងសហករណ៍ភូមិមួយៗ ត្រូវមានប្រធានសហករណ៍ ។ ហើយដកប្រធានសហករណ៍នឹង ភូមិស្វាយនឹងមានលោកតាឡែប ។

ប៊ុនថន ៈ តាឡែប?

វើយ ៈ បាទ! សព្វថ្ងៃគាត់នៅសហរដ្ឋ ។

ប៊ុនថន ៈ គាត់ហ្នឹងប្រធានសហករណ៍?

វើយ ៈ អឺ!នៅក្នុងភូមិមិនមែនប្រធានសហករណ៍ទេ បន្ទាប់ពីប្រធានសហករណ៍នៅក្នុងភូមិ ប្រធានសហករណ៍គឺគេមកពីគេស្រេច ។ ប្រធានសហករណ៍ គេមកចេញពីគេមកធ្វើប្រធានសហករណ៍ ។

ប៊ុនថន ៈ ចុះលោកតាឡែប?

វើយ ៈ លោកតាឡែបនឹងជារងរបស់សហករណ៍ ។ ដូច្នេះគាត់ជាអ្នកគ្រប់គ្រងជំនួសប្រធានសហករណ៍ ។

ប៊ុនថន ៈ គេហៅសហករណ៍អីគេវិញ?

វើយ ៈ ទេ! មិនដឹងជាហៅថាប្រធានសហករណ៍ មិនដឹងដាក់សហករណ៍អី ប៉ុន្តែប្រធានសហករណ៍ភូមិស្វាយ ស្រុកថ្មពួក ។

ប៊ុនថន ៈ ប្រធានសហករណ៍ភូមិស្វាយ?

វើយ ៈ បាទ! ស្រុកថ្មពួក តែមិនដឹងជាប្រធានសហករណ៍ម៉េចៗមិនដឹងទេ មិនយល់ សម័យនោះពិបាកយល់ ។

ប៊ុនថន ៈ ចុះពូការរៀបចំសហករណ៍នឹង ពូចូលកងចល័តនៅ?

វើយ ៈ ខ្ញុំនៅ ខ្ញុំចូលអមចល័តនៅ ទៅចល័តទី១ ខ្ញុំចល័តនៅអាង ។

ប៊ុនថន ៈ អន្លង់ត្រាច?

វើយ ៈ អន្លង់ត្រាច បាទ!ដកខ្ញុំបាទពីអាងអន្លង់ត្រាចនឹងមក ចូលមកអាងជើងគ្រោះ ។

ប៊ុនថន ៈ អាងជើងគ្រោះ?

វើយ ៈ អឺ!

ប៊ុនថន ៈ ត្រពាំងថ្ម?

វើយ ៈ ត្រពាំងថ្ម មិនមែនអាងជើងគ្រោះទេ អាងត្រពាំងថ្ម ។

ប៊ុនថន ៈ ពូទៅធ្វើម្ដងៗរយៈពេលយូរទេ?

រឿយ ៖ បាទ! យូរឆ្នាំ ទៅនឹងមិនមែនទៅ៤-១០មកវិញទេ គឺទៅនឹងអស់រយៈពេលជិតម៉ាឆ្នាំដែរ ដល់នៅនឹងជិតមើល ខ្មែរក្រហមកាន់កាប់ ។

ប៊ុនថន ៖ ៧៥?

រឿយ ៖ ៧៥ ៧៦ បាទ!៧៦ខ្ញុំនៅនឹង ៧៧មិនដល់ឆ្នាំទេ គឺ៧៧ខ្ញុំរត់ទៅថៃវិញ ហើយដោយសារខ្ញុំកាលនៅចល័តនឹងខ្ញុំត្រឡប់មកវិញ ។ ត្រឡប់មកដល់ស្រុកភូមិវិញ ខ្ញុំក៏បបួលគ្នារត់ទៅថៃ ។

ប៊ុនថន ៖ ពូចង់សួរពូផ្លាស់ប្ដូរចៅសង្កាត់ ហើយអឺ!ប្រធានសហករណ៍ ប្រធានកាលនឹងគេហៅប្រធានសហករណ៍?

រឿយ ៖ ប្រធានសហករណ៍ ។

ប៊ុនថន ៖ ផ្លាស់ប្ដូរនឹង ចុះអ្នកដែលផ្លាស់ប្ដូរនឹងទៅណាវិញ?

រឿយ ៖ ដែលអ្នកផ្លាស់ប្ដូរប្រធានសហករណ៍នឹង ទី១មុនដំបូងប្រធានសហករណ៍នឹងឯនៅគ្រប់គ្រងបានតែមិនដល់ម៉ាឆ្នាំផង រយៈពេលតែប៉ុន្មានខែ បង្កើតផ្ទះបាយគេហៅបាយរួមបង្កើតបាន គេយកមួយនឹងទៅបាត់ ។

ប៊ុនថន ៖ គេយកទៅណាវិញ?

រឿយ ៖ មិនដឹង ។

ប៊ុនថន ៖ បាត់រូប?

រឿយ ៖ បាត់រូបស្រាប់តែឃើញមកថ្មីមួយទៀត ។

ប៊ុនថន ៖ ពីណាមកថ្មី?

រឿយ ៖ អឺ! ខ្ញុំភ្លេចតានេះដែលគេយកទៅវ៉ៃ នៅជាប់ភូមិយើងផ្ទះសហករណ៍អឺ!

អ្នកជិតខាង ៖ តាណាគ?

រឿយ ៖ មិនមែនណាគទេ ។ បើតានោះប្រហែលចាំ ខ្ញុំមិនសូវចាំទេ ។

ប៊ុនថន ៖ ចេះចៅសង្កាត់?

រឿយ ៖ ហ្នឹងហើយ ចៅសង្កាត់អត់មានទេ គេដូរមកជាសហករណ៍ ។

ប៊ុនថន ៖ ចៅសង្កាត់ថាផ្លាស់នោះ?

រឿយ ៖ បាទ! ផ្លាស់ប្ដូរចេញមកកន្លែងណាក៏ប្រធានសហករណ៍ ។

ប៊ុនថន ៖ ចេញពីចៅសហករណ៍ចូលមកប្រធានសហករណ៍?

រឿយ ៖ ប្រធានសហករណ៍ ហើយប្រធានសហករណ៍នេះ ឯណាក៏ប្រធានសហករណ៍ តែប្រធានសហករណ៍នេះជាអ្នកគ្រប់គ្រងនៅក្នុងភូមិ ។

ប៊ុនថន ៖ បាទៗ ចឹងដូរពីចៅសង្កាត់មកប្រធានសហករណ៍វិញ?

រឿយ ៖ បាទ! ប្រធានសហករណ៍ជាអ្នកគ្រប់គ្រងនៅក្នុងភូមិ គ្រប់ភូមិទាំងអស់ដូរ ។

ប៊ុនថន ៖ ពូចេញទៅកងចល័តនេះ ទៅច្រើនទេ ភូមិៗស្វាយនេះ?

រឿយ ៖ ភូមិចេញ វាមានចល័តតាមៗលំដាប់ ។

ប៊ុនថន ៖ ពូអាចរៀបរាប់បានទេ?

រឿយ ៖ បាទ! រៀបរាប់តាមលំដាប់ទី១ចល័តខាងវ័យកណ្តាលដែលមានប្រពន្ធកូន កាន់នៅជិតចឹងទៅ ។ លំដាប់ទី២កុមារដែលមានអាយុចាប់ពី៣ឆ្នាំឡើងទៅ អានឹងនៅជិតចឹងទៅ អានឹងចល័តដែលគេចែកឲ្យ ក្រុមាឲ្យនៅធ្វើដូចជាជី ឲ្យនៅបូតស្លឹកឈើធ្វើជីឲ្យអ៊ីជិត ។ រីឯងអ្នកដែលមានកូនវិញ នៅជិតទៅ ។ បើចាស់ៗដែលថាទៅឆ្ងាយមិនបាន ត្រូវការភ្ជួររាស់ ធ្វើស្រែនៅជិតទៅ ។ តែចំពោះក្មេងចល័តមាន២-៣ផ្នែកដូចគ្នា ។ បាទ! ផ្នែកទី១ដកទៅខាងភ្នំស្រុក ត្រពាំងថ្មទៅ មួយទៀតនៅរោងសង្កែហៅថានេះយើង មិញត្រឹមអាងនេះ ។

ប៊ុនថន ៖ អាងត្រពាំងថ្ម?

រឿយ ៖ អត់ទេ នេះអាងអន្លង់ត្រាចៗនេះទៅគេដកមួយចំនួនទៀតនៅខាងជើងគ្រោះទៅ ហើយមួយចំនួនទៀត បានអាចល័តពិសេសទៅខាងភ្នំស្រុក ។

ប៊ុនថន ៖ ចឹងពូនៅខាងចល័ត?

រឿយ ៖ ចល័តពិសេស ប៉ុន្តែពិសេសនេះនឹងមានខាងផ្នែកយុវជនពិសេសមួយទៀត ឯខ្ញុំក៏យុវជនដែរ តែពិសេសទី១ ។ វាមាន២ជាន់ទៀត យកទៅជាន់ទី១ ជាន់ទី២ ដល់ទៅនៅជាន់ទី២នឹងគឺថាសម្រាប់ដឹកនាំគេ ធ្វើអាសមរភូមិទី២ ។ បើអាពិសេស គេសមរភូមិទី១នឹងគឺថាផ្តាច់ព្រាត់ហើយ ការងាររផ្តាច់ព្រាត់តែម្តង ។

ប៊ុនថន ៖ បាទ! ធ្វើសំរុក?

រឿយ ៖ ធ្វើសំរុកកម្លាំងធំអ្នកណាមិនសំនុំដកចេញ ។

ប៊ុនថន ៖ ពូកម្លាំងទី២អស់សូវ?

រឿយ ៖ កម្លាំងទី២ ។

ប៊ុនថន ៖ នៅធ្វើអី?

រឿយ : នៅធ្វើស្រែផង រើសដីបិទទំនប់ខ្លួនឯង តែប្រកបកការងារកសិកម្ម ខាងស្រែណា ខាងស្ទូងដក តែអ្នកដែលម៉ាចំនួនទៀត ខ្ញុំបានទៅនៅខ្ញុំបានកាន់កាប់យុវជន យុវនារី១០០នាក់ ។

ប៊ុនថន : បាន១០០នាក់ដែរ?

រឿយ : បាទ! យុវជន៥០ នារី៥០ ១០០នាក់ ។

ប៊ុនថន : នៅនឹងប្រហែលប្រធានកងទេ?

រឿយ : បាទ! ប្រធានកង ។

ប៊ុនថន : កងតូចកងធំ?

រឿយ : កងតូចទេ ។

ប៊ុនថន : ចេញពីភូមិនឹងទៅដែរ?

រឿយ : ចេញពីភូមិនឹងទៅតែ១០០គត់កូនចៅខ្លួនឯង កំលោះៗនារីខ្លួនឯង មានណាការដឹកនាំគេ គេប្រើអីប្រើទៅ ។

ប៊ុនថន : ចុះនៅនោះការងារភាគច្រើនគេធ្វើអីគេ?

រឿយ : ការងារភាគច្រើនរែកដី បត់ទំនប់ម៉ាចំនួន ម៉ាចំនួនទៀត បែងមកខាងរាស់ ដកស្ទូង ។

ប៊ុនថន : ចឹងពូកាន់កាប់ដឹកនាំកម្លាំងធ្វើទាំង៣ការដ្ឋាននឹង?

រឿយ : តប តាមបញ្ជាគេមកពីលើ ឥឡូវថា ។

ប៊ុនថន : ពូមិញទៅត្រពាំងថ្ម ទៅអន្លង់ត្រាច?

រឿយ : អត់ទេៗ ។

ប៊ុនថន : ទៅត្រពាំងថ្ម?

រឿយ : ទៅតែនោះទេ ឥឡូវទៅខាងខ្ញុំគេឲ្យទៅចេះតែទៅ មកពីនេះវិញ គេដកមកនេះទៅនេះ ទៀតទៅ ។ មិនមែនកាន់កាប់ទាំងរួមអស់ អត់មាន ។

ប៊ុនថន : បាទ! កម្លាំងទាំង១០០នាក់នឹង ពូ?

រឿយ : ១០០នាក់ លុះត្រាតែទៅនោះ ដែលទៅអាងត្រពាំងថ្មនឹងគ្នា.... ។

ប៊ុនថន : ចុះអាហារអី ពូដោះស្រាយខ្លួនឯង ឬក៏ខាងគេ?

រឿយ : គេដោះស្រាយទាំងអស់ ។ បាទ! ទី១ដែលយើងត្រូវដោះ កម្លាំងពិសេសមកហើយ គេក៏ដោះស្រាយដូចថាជាម្ហូប ជាត្រី ជាបាយ បានត្រឹមប៉ុននោះ ២អាទិត្យបាយ ។ មកប្រហុកអំបិលម្ទេសអីទេដឹងថា បានស៊ី២អាទិត្យ ។

ប៊ុនថន : ដល់ពេលក្រោយមក?

វើយ : ក្រោយមកដឹកម្ហូបមិនទាន់ ដឹកអង្ករមិនទាន់ ចឹងចាប់ផ្តើមបបរ ។ ខ្ញុំចាប់ផ្តើមបបរ ស្គាល់ជាតិបបរមិនដែលស្គាល់ជាតិបាយ ។

ប៊ុនថន : ប៉ុនដូចរបបទាហានអីផ្សេង?

វើយ : អត់មានទេ ។ បើរបបដូចថាផ្សេងសម្រាប់យោធាអីខ្ញុំអត់ដឹងទេ បើថារបបអ្នកទាំងអស់គ្នា ទាំងយុវជន ទាំងអ្នកគ្រប់គ្រងដូចគ្នា បបរ ៗទាំងអស់គ្នាអត់ ៗទាំងអស់គ្នា បានស៊ីៗទាំងអស់គ្នា អត់បានស៊ីអត់ ។

ប៊ុនថន : នៅនឹងពីណាអ្នកគ្រប់គ្រងធំជាងគេ ត្រពាំងថ្មនឹង?

វើយ : អូ!

ប៊ុនថន : ការដ្ឋានទាំងមូល?

វើយ : ការដ្ឋានទាំងមូលនឹង អឺ!ខ្ញុំស្គាល់ដូចជាមិនអស់ទេ មិនដឹង ។

ប៊ុនថន : ចុះអ្នកបន្ទាប់ ប្រធានបន្ទាប់ៗ?

វើយ : បន្ទាប់ៗ មានបើអាខ្លះមានសុទ្ធតែទាហានចល័តពិសេសគេ ខាងធំដឹងថាតាវ៉ាល់ៗឈ្មោះតាវ៉ាល់ៗ ។

ប៊ុនថន : តាវ៉ាល់?

វើយ : បាទ! ឈ្មោះតាវ៉ាល់នេះ អ្នកណាគេមួយធ្វើការមិនកើត គឺគេសុំឲ្យបញ្ជូនទៅតាវ៉ាល់ ។

ប៊ុនថន : បាទ! ហ្នឹងចំពោះអ្នកដែលធ្វើការមិនកើតនឹង ធ្វើយ៉ាងម៉េចបានគេនេះគេយក?

វើយ : ដួនកាលយើងមិនមែនជាអ្នកកសិករពិត ហើយស្រាប់តែគេជម្លៀសមកពីភ្នំពេញ មកនៅយើងធ្វើត្រាប់ប្រជាជនធ្វើការនឹង មិនពេញកម្លាំងដូចគេ ព្រោះគ្នាមិនដែលស្គាល់ជាតិថាអាម៉េចរែកដី អាម៉េចស្ទូង ម៉េចដកគ្នាអត់ដឹង ។ ហ្នឹងស្រាប់តែ បើធ្វើអីមួយដែលលំបាកប្រាប់ទៅតាវ៉ាល់ ។ ចឹងកងគេមកៗយកហើយ គេយកទៅបង្រៀន យកទៅនាំធ្វើវាម៉េចដឹងទេ ។

ប៊ុនថន : ប៉ុនអ្នកនឹងមកវិញទេ?

វើយ : អឺ! អត់មានទេ តែដកពីយើងទៅបាត់ហើយ ។

ប៊ុនថន : ចុះមានកំណត់ឲ្យធ្វើទេ ពូដូចថា ដូចពូទៅម៉ាកងតូចចឹង គេកំណត់ឲ្យយកប៉ុន្មាន?

វើយ : ឲ្យធ្វើកំណត់ថាឥឡូវ កងចល័តខាងថ្មពួកប៉ុន្មានម៉ែត្រក្នុងម៉ាថ្ងៃៗគេចែកគេបែងចែកឲ្យមក យករួច ទាល់តែរួច ។

ប៊ុនថន : បើមិនរួច?

វើយ : បើមិនរួចខ្លាចគេតិះទៀន គេធ្វើ ។

ប៊ុនថន : ចឹងអ្នួលដែលអត់ធ្វើ និយាយថាធ្វើអត់ពេញដៃអត់ពេញជើងចឹង ប្រធានកងគេ ប្រធានកងនឹងរាយការណ៍ទៅលើ?

វើយ : រាយការណ៍ទៅលើ តែបើថាយើងនៅស្រុកភូមិយើងចេះ មិនដែលមានអ្នកណាមួយយើងមិនបាច់រាយទេ ធ្វើគេឲ្យទៅធ្វើ គិតតែធ្វើដេកទាំងហេវ ចុះបបរមិនស្គាល់ជាតិអី ។

ប៊ុនថន : ចឹងប្រធាននៅកងលោកពូនឹងមានអ្នកថ្មីចូលលាយឡំទេ?

វើយ : អត់មានទេ ស្រុកភូមិយើង ។

ប៊ុនថន : តែអ្នកស្រុកនៅ?

វើយ : អត់មានកងចល័តមកពីណា អ្នកជម្លៀសមកពីណាចូលអត់មាន ។

ប៊ុនថន : បាទ! ប៉ុនកងផ្សេង មានទេពូ?

វើយ : មិនដែលមានទេ បើសម្រាប់ស្រុកថ្នួក ដែលមានទៅពាកងមិនដែលមានទេ ។ បើមកពីគេនោះចូលខាងភ្នំស្រុក ខាងព្រះនេត្រព្រះអានឹងមិនដឹងទេ ប៉ុន្តែមានតែតាវ៉ាល់ទេ ជាអ្នកគ្រប់គ្រងកង ។

ប៊ុនថន : កងពិសេសហ្នឹង?

វើយ : បាទ! កងពិសេស ។

ប៊ុនថន : ចុះលើគាត់ អ៊ំដូចមាន?

វើយ : អូ!ខ្ញុំមិនស្គាល់ទេ ដឹងថាអ្នកណាមួយ ហើយដូចជាប្រធានភូមិភាគនឹងមានដូចឈ្មោះ?

ប៊ុនថន : តាញឹមលោកពូ?

វើយ : បាទៗ តាញឹម ហ្នឹងគេថាគាត់គ្រប់គ្រង ។ ចឹងតាញឹមគឺគាត់បានតែសម្រាប់គ្រប់គ្រងទេ ហើយគាត់ក៏មិនដឹងទៅជាទៅណាស្លាប់ ឬក៏រស់ក៏គាត់មិនជាអ្នករស់ទៅទេ ។

ប៊ុនថន : ចឹងតាវ៉ាល់នឹងនៅគ្រប់គ្រងពូរហូត ហើយដល់?

វើយ : អឺ! តាវ៉ាល់នឹងនៅគ្រប់គ្រងកន្លែងនឹងរហូត នៅគ្រប់គ្រងកន្លែងនឹងរហូត ជាពិសេសខ្ញុំបាន បញ្ហាសំខាន់គឺតាវ៉ាល់ ដំណើរការដែលដើរកើត ឬមិនកើត លើតាវ៉ាល់ ។

ប៊ុនថន : នៅនឹងតំបន់ប៉ុន្មានពូ នៅក្នុងតំបន់ប៉ុន្មាន?

វើយ : ភូមិភាគ៥ ។

ប៊ុនថន : ភូមិភាគ៥ ?

វើយ ៖ បាទ!

ប៊ុនថន ៖ តំបន់៥?

វើយ ៖ បាទៗ ។

ប៊ុនថន ៖ បាទ! ពូនៅនោះបានប៉ុន្មាន រយៈពេលប៉ុន្មាន?

វើយ ៖ ខ្ញុំនៅ ។

ប៊ុនថន ៖ ត្រពាំងថ្ម?

វើយ ៖ ត្រពាំងថ្ម ដូចជាមិនបានមួយឆ្នាំទេ តាមមើល ព្រោះមិនបានជាអត់ មិនបានជាគិតខែគិតថ្ងៃគិតពេលវេលា ប៉ុន្តែមិនបានមួយឆ្នាំទេ បើអាកងពិសេសទី១ បានម៉ាឆ្នាំ ។

ប៊ុនថន ៖ កងពិសេសទី១?

វើយ ៖ ទី១ ។

ប៊ុនថន ៖ ហ្នឹងនៅណាវិញ?

វើយ ៖ ហ្នឹងទៅមុនៗខ្ញុំ នៅនោះដែរ ។

ប៊ុនថន ៖ បាទ! នៅនោះដែរ?

វើយ ៖ បាទ! នៅបានម៉ាឆ្នាំ ប៉ុនខ្ញុំមិនបាន ។

ប៊ុនថន ៖ គេៗដឹកនាំផ្សេង?

វើយ ៖ គេដឹកនាំផ្សេងៗ ។

ប៊ុនថន ៖ ពីណាគេអ្នកដឹកនាំ?

វើយ ៖ ទេ! កាលនោះឈ្មោះ គាត់នៅផ្ទះគេ ភូមិផ្សើង ខ្ញុំមិនស្គាល់ទេ វាភ្លេចឈ្មោះ ហ្នឹងវាទៅជាន់ទី១ លំដាប់ទី២ខ្ញុំចេញទៅ ។ អាពួកនោះ គេទៅនៅបានម៉ាឆ្នាំហើយគេចេញ ធ្វើការទៅនៅបែងចែកទៅនៅខាងអូររំចេក អូរអើណានោះ ។ ហ្នឹងជាន់ទី១ ចែកគ្នាបើខ្ញុំទៅក្រោយ អត់បានចែកទេ ។

ប៊ុនថន ៖ ចឹងពូមកវិញនឹង កម្លាំងពូត្រឡប់មកវិញទាំងអស់?

វើយ ៖ អត់ទេៗ ខ្ញុំមកដោយការលួចលាក់របស់ខ្ញុំ តែបើតាមមើលទៅខ្ញុំដូចខ្ញុំគ្មានការសង្ឃឹមការរស់នៅ ។

ប៊ុនថន ៖ យ៉ាងម៉េចទៅ?

វើយ ៖ បើបបរក៏បបរ ធ្វើការក៏ខ្លាំងវេទនាគ្រប់បែបយ៉ាងទាំងអស់ ចឹងខ្ញុំមានគំនិតមួយត្រូវតែប្រមូលគ្នា រត់ចេញពីការកាន់កាប់របស់៣ឆ្នាំ៨ខែ របស់ខ្មែរក្រហម ខ្ញុំត្រូវតែរត់ចេញ ។

ចឹងខ្ញុំក៏សុំច្បាប់គេ ត្រឡប់មកភូមិវិញ។ ខ្ញុំមកបានម៉ាអាទិត្យ ដល់បានម៉ាអាទិត្យគេបញ្ជូនខ្ញុំឲ្យទៅវិញ តែខ្ញុំអត់ទៅ គេក៏បញ្ជូនខ្ញុំឲ្យទៅនៅខាងចល័ត។ តាៗយើងចល័តចាស់ៗនឹងខាងភ្ជួររាស់។

ប៊ុនថន : ភ្ជួររាស់?

រើយ : ភ្ជួររាស់ៗនៅវាលធំយើងខាងកើតនេះ។

ប៊ុនថន : វាលធំនៅណា នៅភូមិស្វាយនឹងដែរ?

រើយ : ភូមិស្វាយនឹងដែរ វាលខាងកើត។ ហើយខ្ញុំក៏ទៅនៅរួមជាមួយតាៗទាំងអស់គ្នាទៅ ខែភ្ជួរចាប់ផ្ដើមភ្ជួរដើម្បីធ្វើជាស្រែ ភ្ជួររាស់ ដកស្ទូងចឹង មិនត្រឹមដកស្ទូងទេ យើងភ្ជួររាស់បញ្ជូនកម្លាំងឲ្យទៅ។ ហើយខ្ញុំក៏បានទៅរួមនឹងគេ ដល់ទៅរួមនឹងគេទៅមានគំនិតមួយថាអញត្រូវទៅថៃ អ្នកណាទៅក៏ដោយ អ្នកណាមិនទៅក៏ដោយ អញត្រូវតែទៅ។ ចឹងខ្ញុំក៏បានគ្រោងការណ៍ ប្រធានសហករណ៍អត់ដឹងទេ ក៏បាននាំគ្នារត់ទៅប្រទេសថៃ។

ប៊ុនថន : នេះដោយសារធ្វើការខ្លាំងពេក ឬមួយម៉េចបានចឹង?

រើយ : ដោយសារធ្វើការខ្លាំងពេក ហើយទី១មិនដឹងថាយើងរស់ ឬស្លាប់ បើយើងនៅសង្គមនោះ លោកដែលជាចៅសង្កាត់លោកប្រធានសហរកណ៍។ លោកដែលជាប្រធានសហករណ៍ហ្នឹង បានឋានៈធ្វើជាប្រធានសហករណ៍សមមុខនឹងគេហើយ ដូចថាកងយោធាគេមកធ្វើ ហើយប្រធានសហករណ៍។ តែដកមកវិញបាត់ឈឹង បានសេចក្ដីថាអាប្រធានសហករណ៍នឹង ខុសគេយកទៅវ៉ៃចោល វ៉ៃតែគ្នាវាទេ។ ចឹងយើងជាអ្នកនៅខាងក្រោម មិនដឹងជាថ្ងៃណាមួយអញត្រូវគេយកទៅវ៉ៃដែរ។ ចឹងក៏ហើយជាពិសេសទៀតយើងនើយ ណាយនឹងការហត់រៀន បបរហេវហត់ខ្លាំង ស៊ូមិនបាន។ ចឹងមានគំនិតមួយបបរគ្នា។ ខ្ញុំក៏បានចេញពីក្នុងព្រៃនឹងមកៗភូមិនេះ មកដល់សំលុតយកគ្នាឯង “នេះឯងទៅថៃអត់”។ មានអាក្លួយម្នាក់នោះនៅគោករមៀត គេទៅនោះគេស្គាល់គេដឹង “ទៅថៃម៉េចចេះទៅដែររស់ ទៅស្លាប់”។ “ឯងស្គាល់ទឹកដីនោះ ផ្លូវទៅ រត់តាមនេះបើទៅចាក់ស្លាប់នឹង” សំលុតគេទៀត។

ប៊ុនថន : កាលនោះពូមកបានប៉ុន្មាននាក់?

រើយ : មកៗពីនោះ មកតែខ្ញុំទេ តែបបួលនេះបានច្រើនដែរ។ បបួលគ្នាស្ងាត់ៗ អត់ហ៊ាននិយាយខ្លាំង បែកការណ៍អីទេ ងាប់។

ប៊ុនថន : ពូសំលុតម៉ង អ្នកនេះ?

វើយ ៖ គ្នាឯងសំលុតឲ្យចេញ បើមិនទៅកាប់ផាប់ "ទៅប្រទេសថៃមែន"ថាចេះ កុំអីវាអត់ទៅចឹង បានវាទៅ ។ បាទ! ថ្ងៃមួយនាំគ្នា មុននឹងពេលចេញទៅរយៈពេលម៉ោងអាទិត្យនឹង បបួលគ្នា បានប្រហែលជា១០នាក់ ។ បាទ! ១០នាក់នឹងត្រូវការត្រៀមម្ហូបទៅ លួចពីនេះទៅយកទៅវ៉ៃស៊ីទៀត ។

ប៊ុនថន ៖ លួចបានអី?

វើយ ៖ បានជ្រូក និងគោ នាំគ្នាវ៉ៃស៊ី ស្ងាត់ៗ វ៉ៃស្ងាត់ស៊ីរួចទៅ ចុះយើងបានអង្ករណាទៅ អង្ករគេយកអាកុមារចល័តចាប់ពីអាយុ៣ឆ្នាំឡើងទៅ៦-៧ឆ្នាំ វានៅចល័តនឹងគោកកើតនេះគេហៅគោកត្រពាំងអំពិល ។ ចឹងអាគោកត្រពាំងអំពិលពួកកុមារចល័តនៅនឹង យប់ឡើងនាំគ្នាដេកស្ងាត់ យើងក៏នាំគ្នាទៅលួចអង្ករយកទៅ យកម្ហូបយកអីទៅ គ្មានម្ហូបអីទេ មានតែអង្ករបានអង្ករ ។ ហើយស្មានតែយកអង្ករនឹងទៅ បានដាំបាយស៊ី ឬក៏ធ្វើអីអត់បានទេ នឹកស្មានតែទៅនឹង មិនដឹងជាអ្នកបានប៉ុន្មានថ្ងៃ ក៏ចេះតែរកអង្ករលួចអង្ករពួកកុមារនឹងៗគ្នាអត់ស៊ី ។ ចុះបើអាចោរប្លន់យកទៅហើយ អាចោរប្រាសស្រុកប្លន់យកទៅទៀត គ្នាបានអីស៊ី អត់បានទេ នាំគ្នាចែកគ្នាវេចគេម្នាក់តិចៗ គេក៏វេចទៅ យើងក៏វេចទៅ ចែកគ្នា មិនដឹងប៉ុន្មានថ្ងៃបានទៅដល់ មិនដឹងថាឆ្ងាយប៉ុន្មាន ជិតប៉ុន្មានអត់ដឹងទេ បើដឹងជាជិតប៉ុននេះរត់តាំងពីដំបូងម៉េច ។

ប៊ុនថន ៖ ពូអត់ដែលទៅទេ ពីមុនមក?

វើយ ៖ មិនដែលៗស្គាល់ទេ ត្រង់ណាព្រំដែនថៃ នៅត្រង់ណាមិនដែលស្គាល់ ឮតែគេថាថៃជិតព្រំដែនក៏ជិតនឹងគេទៅ ។ មិនដឹងថាព្រំដែននៅចំងាយប៉ុន្មានគីឡូ មិនដឹង ។ បើដឹងថារត់តែម៉ោយប់ម៉ាថ្ងៃដល់ មិនទាន់បានពួកនោះគ្រប់គ្រងបាត់អស់ ។

ប៊ុនថន ៖ ចុះពូរត់ចេញពីភូមិយ៉ាងម៉េចទៀតទៅ?

វើយ ៖ ការរត់ចេញ គឺថាចាប់ផ្ដើមរត់ចេញពីម៉ោង៧យប់នឹង ចាប់ផ្ដើមចេញ ។ ចឹងក្នុងគ្នា៨-១០នាក់នឹង ដែលពិគ្រោះគ្នាហើយ ប្រមូលរួមគ្នា អ្នកផ្សេងមិនដឹងជាគេដឹង តែខ្ញុំនាំគ្នារត់ទៅអ្នកនោះចេះរត់តាមបានប្រហែលជា១៥នាក់រត់ ។ ១៥នាក់នឹងថាចេញ ធ្វើដំណើរថាអត់ឲ្យប្រធានសហករណ៍ខាងសេដ្ឋកិច្ចក្នុងភូមិ អត់មានឲ្យខាងសេដ្ឋកិច្ចអីដឹងទេ គឺរត់ចេញម៉ង ទៅនឹងទៅព្រៀវ ដូចខ្ញុំថាចាប់មេខ្យល់បានមួយដើរមុខ ។ នឹងចេញធ្វើដំណើរចេញទៅចេះឆ្លងថ្នល់ៗបន្ទាយឆ្មារ ថ្មពួកៗផុត ចាប់ផ្ដើមវង្វេងហើយ ។ វិលទៅវិលមករុកព្រៃទៅមកៗមកជួបភូមិគេ ភូមិតាយឹង ។

ប៊ុនថន : ភូមិតាយឹង?

វើយ : បាទ!

ប៊ុនថន : ហ្នឹងនៅឃុំអីគេ?

វើយ : ឃុំថ្មពួកនេះដដែល ចេញទៅវិញទៀតទៅភូមិគេផ្សេងៗ អឺ!នាំគ្នារត់បកទៅវិញ បកទៅដើរទៀតហើយ ទៅរេៗទៅជិតកណ្ដោល តាយឹងកណ្ដោលៗ មកដល់កណ្ដោលទៀតទៀតហើយភូមិទៀត ឆ្កែនាំគ្នាដកថយទៅវិញទៀត ស្រុកនៅនេះផង ប៉ុននាំផ្លូវមិនច្បាស់ចេះយប់នោះ អាកខានយូរហើយៗ អឺ! ចេញទៅវិញ ទៅដើររៀបភ្លឺ ឆ្លងផុតភូមិគោករមៀត ផុតកណ្ដោល ផុតភូមិគោករមៀតៗ ទៀបភ្លឺម៉ោង៤ ជួបពួកខ្មែរក្រហមដែលគេដេកយាមផ្លូវៗ ចឹងដេក ពួកខ្មែរក្រហមវានៅក្រវ៉ាត់ផ្លូវព្រំដែននៅនឹង ផ្លូវទី១ ផ្លូវទី២ ផ្លូវទី៣ ៣ផ្លូវដែលគេយាមៗ ទី១គេធ្វើរបង ដែលយកប្រជាពលរដ្ឋទៅធ្វើរបងដូចគេហៅថាធ្វើក្រោលគោរបងៗ

ប៊ុនថន : បាទ! របងការពារ ព័ទ្ធ?

វើយ : បាទ! ព្រំដែនៗ របងនឹងកាប់មែកឈើដាក់ កាប់បន្លាដាក់ជុំវិញទី១ៗ ចឹងចល័តពីផ្លូវទី២គេជីរះៗផ្លូវទទឹងប្រហែលជា៥ម៉ែត្រ អឺ!១០ម៉ែត្រទៅ២០ម៉ែត្រឲ្យស្អាត អានឹងគេបរចឹងហើយៗ ភ្លឺឡើងយោធាគេដឹកមកហើយ មកមើលដំឡូងអ្នកណាឆ្លងកាត់ បើឆ្លងកាត់ឃើញដំឡូងៗ

ប៊ុនថន : ឃើញស្នាមជើង?

វើយ : បាទ! ឃើញស្នាមជើង ឆ្លងកាត់ប៉ុន្មានៗនាក់ៗដឹង ដូច្នេះរាយការណ៍ទៅពួកនោះវិញភ្លាមដល់ខ្សែត្រៀមចុង ទី៣ៗ

ប៊ុនថន : ទី៣នឹងគេដាក់ម៉េចវិញ?

វើយ : អានឹងនៅយាមនៅនឹង ការពារផ្លូវដូចគ្នា តែត្រង់ថាអាទី២ហ្នឹងគេឃើញដំឡូងឆ្លងកាត់យប់មិញនេះរៀបព្រឹក ប្រហែលជាម៉ោង៤ ឬម៉ោង៥ដំឡូងឆ្លងកាត់ចេញទៅថៃហើយៗ ចឹងអាខ្សែត្រៀមនៅទី៣ចុងក្រោយហ្នឹង ត្រៀមហើយ គិតគ្នាចឹងៗ តែកាលណាយើងទៅប៉ះគេនឹងដឹងថាស្លាប់ហើយ តិចៗ

ប៊ុនថន : ចុះពូៗចូលទៅយ៉ាងម៉េច?

វើយ : បាទ! ក្នុងចំណោមពួកខ្ញុំបានចូលទៅដល់ប៉ះកន្លែងពួកដេក កន្លែងគេយាមថយក្រោយមកវិញ បែកគ្នាអស់ៗ ដល់បែកអស់មានខ្ញុំ បើជាប់នឹងខ្ញុំ គឺជាប់គ្នា៣នាក់ៗ បាទ! ក្រៅពី

នឹងម៉ាប៉ែកទៀត មិនដឹងប៉ុន្មាននាក់ទេ គឺបែកគ្នារត់អស់ រៀងខ្លួនៗ បាទ! ដល់ប្រហែល ជាម៉ោង៧ពួសូរកាំភ្លើងបណ្ដោយ ចឹងៗ

ប៊ុនថន : ពួច្រើនគ្រាប់ទេ ផ្ទុះកាំភ្លើង?

វើយ : អាពួ៣គ្រាប់ៗ ថាអស់បាត់ហើយ អានឹងស្មានទេៗ

ប៊ុនថន : បាទៗ ប៉ុនពូភ័យទេ?

វើយ : និយាយមិនភ័យៗហើយពួកខ្ញុំអត់ទៅណារួចទេ ជាប់ហើយជាប់ខ្សែត្រៀមគេៗ

ប៊ុនថន : បាទ! នៅជិតកន្លែងយាមគេដែរ?

វើយ : ខ្ញុំនៅជាប់កន្លែងផ្លូវគេយាម ផ្លូវដើរអត់ហ៊ានឆ្លង ពួកអាអស់នោះមិនដឹងជាអ្នកណាធ្វើបែក មិនដឹងជិតគ្នា បែកឆ្ងាយណាស់ ស្រាប់តែពួសូរនាំគ្នារត់អស់ ពួសូរបែកគ្នាអស់ៗ ហើយ នៅជាប់ខ្ញុំ មានខ្ញុំ ហើយលោកគ្រូឈើមៗ

ប៊ុនថន : បាទ! គាត់នៅរស់ទេ?

វើយ : សព្វថ្ងៃរស់ ហៅថាលោកគ្រូឈើម គាត់បង្រៀនខាងសាលាកាលេះ ខាងវិទ្យាល័យៗ

ប៊ុនថន : បាទ! ពីណាទៀត?

វើយ : ហើយ មួយទៀតនឹងលោកភ្លៀនៗ នៅខាងសេដ្ឋកិច្ចពីដើមពីសម័យនោះ បានរត់ទៅដែរ ពួតាមគេតាមឯង រត់តាមទៅដែរៗ ដល់រត់ទៅគាត់ក៏លោកភ្លៀននឹងសព្វថ្ងៃគាត់នៅ សហរដ្ឋៗ បាននៅតែខ្ញុំនិងលោកគ្រូឈើម មិនបានទៅណានឹងគេ នៅៗ ហើយ៣នាក់ នឹង ក្រាបតែម្ដង គេដើរមកចេះដើរច្រវ៉ាក់ឡើង ហើយយើងមុននឹងឆ្លងឃើញគេដើរមក នាំគ្នា ដេកពួននឹងព្រៃកំពកប៉ុនៗនេះ កំពស់មួយម៉ែត្រជាង ចែកគ្នាដេកទៅ បានខ្ញុំអត់ឆ្លង ទេ អត់ហ៊ានឆ្លងៗ ភ្លឺៗព្រឹកឡើងម៉ោង៧-៨ អត់ហ៊ានឆ្លង គេក៏ដើរទៅមកៗរហូតដល់ ប្រហែលជាម៉ោង១២ ពេលវេលាដែលគេត្រូវបាយៗ ចឹងស្ងាត់ៗនឹងការដើរចល័ត របស់គេៗ ចឹងអើតមើលឃើញផ្លូវចេះឯង មើលឃើញ លូនទៅមើល ធ្វើការលូនទៅ មើលផ្លូវដែលធ្លាប់ធ្វើដំណើរនឹង យើងលូនទៅមើលផាកទៅខាងឆ្វេង ផាកទៅខាងស្ដាំ ដល់ផាក ទៅយើងមិនឃើញ មានណា ហៅគ្នាយើងឲ្យមកអែបនិងផ្លូវទាំងអស់គ្នាសិន មកៗ ដល់ពេលគេមកដល់ចឹងទៅ ថ្ងៃដល់ម៉ោងគេសម្រាកហើយ នាំគ្នាក្រោករត់សំរុក ទៅៗ

ប៊ុនថន : រត់ទៅតាមផ្លូវដើរ?

វើយ ៖ អត់មានផ្លូវទេ កាត់ព្រៃ កាត់ដុះមានចំរូង គេផុតពីផ្លូវទឹកនឹង ឆ្លងបានផុតហើយ មកនៅចំរូងៗម៉ាម៉ែត្រមួយៗ គេជីកគេត្រែបាយខុម(រង្វង់ៗមូល) អានេះអន្ទង់មួយៗៗ បើយើងគេចពីអានេះផុតមកអានេះ មកធ្លាក់អានេះ បើគេចពីអានោះធ្លាក់មកអានេះ គេធ្វើរៀងៗ

ប៊ុនថន ៖ ត្រីកោណ?

វើយ ៖ ត្រីកោណ បាទ!អន្ទង់ ហើយដៃយើងអត់ឃើញទេ ហើយអន្ទង់នោះម៉ាម៉ែត្រកន្លះទទឹងអឺ!បណ្ដោយ ទទឹងម៉ាម៉ែត្រក្នុងអន្ទង់មួយនឹងៗ ដាក់ឫស្សីដែលឲ្យអ្នកស្រុកយើងនឹងឯងពួកចាស់ៗដែលមានអាយុ៥០-៦០-៧០នឹង អង្គុយបិទចំរូង ម៉េចថាបិទចំរូង គេយកឫស្សីមក គេសំរួចៗចុងសំរួចដើម ហើយកំពស់ប៉ុនៗនេះ សំរួចចុងសំរួចដើម នឹងគេហៅថាអ្នកធ្វើចំរូង ចាស់ៗដែលរែកទឹកក៏មិនកើត ធ្វើអីមិនកើត ថាចាស់ៗនឹងថាមិនអត់ប្រយោជន៍ទេ ចាស់សម័យនឹង មិនចេះអត់ប្រយោជន៍ទេៗ

ប៊ុនថន ៖ បាទ! ឲ្យបិទចំរូង?

វើយ ៖ ឲ្យបិទចំរូង បិទនឹងគឺថាហួសបួនឯងមកហើយ ម៉ាម៉ែត្រ២ទឹក កំពស់វាសំរួចចុងសំរួចដើម ចងបាច់ឲ្យគេៗ ម៉ាបាច់១០ដើមទៅ២០ដើម ចងបាច់ឲ្យគេៗ យើងសំរួចបានចងៗ ហើយបញ្ជូនយកទៅឲ្យៗ ហើយទៅដល់នោះយោធាគេទេ គេជាអ្នកជីក គេជាអ្នកធ្វើមិនមានស្លាប់ មិនមានយុវជនណាទៅដឹងពន្ធឺអត់មានទេៗ ដូច្នេះក្នុងអន្ទង់នឹងមិនដឹងជាប៉ុន្មាន ចំរូងទេមើលទៅច្រូងៗ អាល្មមយើងធ្លាក់ទៅវាសមនឹងឫស្សីដែលគេសំរួចនឹង យកបុកមុតយើង ហើយក៏ស្រវ៉ាចាប់ឯណា បើយើងធ្លាក់ទៅក្នុងអន្ទង់នោះ អាចំរូងនោះក៏មុត ទៅស្រវ៉ាអីជួយ អត់ទេ ដឹងថាទៅមុខហើយៗ

ប៊ុនថន ៖ ចុះអ៊ំធ្វើម៉េចបានរួច?

វើយ ៖ បានហ្នឹង បានខ្ញុំមានលោកគ្រូនេះគេគិតបាននេះដែរ ជួនកាលយើងមិនអាចរត់ចំបានទាំងអស់ទេ អាកន្លែងណាស្មៅខ្ពស់ៗ សម័យនេះស្មៅ អត់មានអ្នកណាហ៊ានថយ ពំនូកខ្ពស់កុំទៅ ដឹងទៀត ដឹងតាមខ្សែរយៈនឹងឯង កុំឲ្យទៅៗ ចុះខ្ញុំឈើមួយ គ្នាខ្ញុំ៣នាក់ឈើម្នាក់ មួយៗទៅ រត់បណ្ដោយចាក់បណ្ដើរ ចាក់ចេះវាស្រឡុះខ្លាំង យើងអត់ហ៊ានទៅទេ ដឹងគេចំនុំគ្នាម៉េច វាចេះមានប្រឡោះៗទៅដល់កន្លែងជិតចូលព្រំដែនៗ ដល់នេះឯងសួរថានេះ ព្រំដែននេះចឹងឆ្លង មីនបិតាមីនទៅទទួលឃើញមែកឈើមួយ មិនមែនមែកទេដើមឈើមួយដួលទន្ទឹមនឹង យើងឡើងទៅក្រោយៗ វាដួលមុន យី!ស្លាប់ៗទៅឡើងគាប់

អានេះទៅ ឡើងតាមឈើនេះ អាណាគេដាក់មីនលើឈើកើតទេ ។ ដល់កន្លែងចុះ អាកន្លែងឡើងនេះ យើងយកឈើដែលកាន់នោះ ឃើញដែលឃើញតែខ្សែៗមីន ។

ប៊ុនថន : ខ្សែលើដើមឈើនឹង?

វើយ : ដាក់ចុង ។

ប៊ុនថន : ចុង?

វើយ : បាទ!មុននឹងយើងឡើងលើឈើនឹង ឃើញខ្សែនឹងដាក់អាចុង ។ ចឹងយើងដឹងមុនហើយ យើងអត់ឲ្យគ្រោះថ្នាក់ដល់ខ្លួនបានទេ វាមិនពិបាកក្រលងទេ ព្រោះអត់ដាក់គឹង ដូចយើងដាក់ដើម្បីប្រហារជីវិតភ្លាមៗទេអានោះ ដាក់ប្រឡាក់ខ្សែធូរអូស ចឹងដើងជាន់ល្មមៗអត់ផ្ទុះទេ បើយើងចាប់អារម្មណ៍ ។ តែបើផ្ទុះមួយហើយ ផ្ទុះ៣-៤នោះ ។

ប៊ុនថន : ចាក់ជាប់គ្នា?

វើយ : វាចាក់ជាប់គ្នា ចឹងយើងចេះក្រលងនឹងគេ ក្រលងបានផុត ជាន់ឈើក្រលងបានផុត ឆ្លងអូរអាអូរព្រំដែនយើងនេះ ។ ឆ្លងអូរនោះផុតទៅនៅដីថៃទៀត អត់ដឹងដីថៃ ដីខ្មែរទេ នឹងមីនដែរ ។

ប៊ុនថន : ខាងណាដាក់?

វើយ : ខ្មែរ ។

ប៊ុនថន : នៅខ្មែរដាក់?

វើយ : បាទ! ពួកយោធា ពួកកងទ័ពជាតិយោធាខាងខ្មែរក្រហមវាដាក់ដែរ បានដាក់រួចបានថៃម្តង តែថៃវាអត់ដាក់ទេ ប៉ុនយើងមិនដឹងថាថៃ ឬក៏ខ្មែរ ។ បាទ! ដល់ពួកអាថៃក៏និយាយខ្មែរដែរ បើវ៉ាដ្យូក៏វ៉ាដ្យូខ្មែរ ដែលរស់ឆ្លងប៉ុននេះមិនផុតទៀត ។ បាននាំគ្នាអន្ទុយគិតគ្នា ៣នាក់ អន្ទុយគិតៗ ងាប់ៗទៅអត់បាយម៉ាយប់២ថ្ងៃហើយ បើមិនទៅរកបាយស៊ីដែររស់ ។ ចឹងស្មានថាខ្មែរដល់ទៅបើវិទ្យុក៏ខ្មែរ និយាយក៏ខ្មែរដល់សួរថាថៃ ។ ដល់ពេលទៅជិត ឃើញអូ!កូនឯងខ្មែរៗរត់ឆ្លងដែនទាំងអស់ ។ ចឹងកូនឯងខ្មែរៗ ខ្ញុំក៏ខ្មែរ ខ្ញុំក៏ខ្មែរដែរ កូនអើយមិនដែលស្គាល់ជាតិបាយ ។ ដល់ពេល នែក!ដល់គេថាខ្មែរហើយក៏ខ្មែរនឹងគេទៅមិនដែលស្គាល់ជាតិបាយ ស៊ីគ្នា៣នាក់ ប៉ុននេះស៊ីមិនឆ្អែត ។

ប៊ុនថន : គេដាំឲ្យហូប?

រើយ : បាទ! គេដាំឲ្យហូបៗ ។ ដាំបានគ្នា៣នាក់គិតទៅមិនដែលស្គាល់ជាតិចាប់ទៅ ថាកុំភ័យខ្ញុំខ្មែរទេ អឺ!ខ្ញុំថៃទេ ថៃនិយាយតែខ្មែរ ដូចមិនទុកចិត្ត ងាប់មិនស៊ីសិន ស៊ីបានឆ្អែតនិយាយវ៉ៃ ចោលឥឡូវ តែមិនស្រួលវ៉ៃមែន ម៉ាម៉ាត់ទៅទៀត ។

ប៊ុនថន : គាត់មានកាំភ្លើង?

រើយ : មានអីបើប្រុសមួយស្រី អឺ! ស្រីមួយម៉ែមួយកូន២ កូនស្រី២ ។ ចឹងចេះសួរ “ម៉ែថៃហើយខ្មែរ” ថា “ម៉ែថៃ” “ចឹងម៉េចបានម៉ែឯងនិយាយខ្មែរ” “ចុះជាប់ព្រំដែនតែគ្នានិយាយតែខ្មែរចេះឯង មិនបាច់ភ័យទេ ។ “ចាំតិចទៀត ខ្ញុំហៅនែក!ទាហានថៃឲ្យមកជួបមិនបាច់ ភ័យទេ” “ហ៎! ខ្មែរមែន ហើយថៃមែន” ។ ស្រាប់តែដល់ម៉ោង៣ក៏ឃើញទាហានមក មែន ។ ហើយយើងអត់ស្គាល់ណា ទាហានថៃឃើញឈប់មក ។ ដល់ឃើញពួកអាទាហាន នោះមកវាថាកុំរត់ៗ តែរត់ងាប់ គាត់ប្រាប់ទៀតតែផ្អើលគេងាប់ខ្លួនឯង ។ ហើយបើគេ មិនជឿយើង គេរុញឲ្យយើងវិលទៅប្រទេសខ្មែរវិញ កុំទៅកុំជឿ កូនឯងត្រូវតាំងចិត្តថា មកដល់ហើយ ទោះបីគេឆោតកុហកយ៉ាងណាកុំរត់ទៅវិញកុំវិលវិញ ស៊ូគេវ៉ៃគេធ្វើបាបយ៉ាងណាក៏ដោយ គឺហាមកុំមាត់ តែរត់ងាប់ខ្លួនឯង ។

ប៊ុនថន : បាទ! គាត់ប្រាប់ចឹង?

រើយ : បាទ! គាត់ប្រាប់ស្រេច ។ ចឹងបើទាហាននេះគេមក វាមិននិយាយទេខ្មែរ វានិយាយតែថៃ ។ ដល់និយាយថៃ គេបញ្ជូនកូនឯងទៅវ៉ៃដិប្រំផាត់ រុញឲ្យទៅវិញ កុំឲ្យទៅឲ្យសោះទៅងាប់ហើយ ។ ហ្នឹងខ្ញុំគ្នា៣នាក់តស៊ូហើយ មកមែន ឃើញព័ន្ធ ទាហានគេព័ន្ធគ្រប់ទិសទីគេមិនចង់អីទេ តែមកដល់គេសួរជាពត៌មានថា “ខ្មែរ ពិត.......មានដែលធ្វើកងទ័ពទេដែល ធ្វើទ័ពជាតិទេ?” ថា “មិនដែលធ្វើទេ” “អាប៉ុលពត?” ថា “មិនដែលធ្វើទេ” ។

ប៊ុនថន : ចេះនិយាយថៃ ឬមួយនិយាយ?

រើយ : វានិយាយថៃ ហើយអ្នកបក អាខ្មែរដែលប្រទេសថៃគេបកឲ្យ ។ “មកនេះមកដើម្បីអី?” ថា “ខ្ញុំស៊ូទ្រាំនឹងការអត់ឃ្លានមិនបាន ស៊ីតែបបរ ធ្វើការទាំងយប់ទាំងថ្ងៃ ស៊ូមិនបានទេ ខ្ញុំសុំរស់នៅនឹងថៃ ឲ្យថៃជួយ” ។ “ហើយពួកនេះឯងទាហានប៉ុលពត” “មិនដែលបានស្គាល់ទេទាហានប៉ុលពត មិនដែលបានធ្វើទេ” “ទៅវិញ បញ្ជូនឯងដូចឯងនិយាយប្រាប់ បញ្ជូនមក” ចងមុខប្រឹប ចងបិទភ្នែកទៅវិញ “ទាហានប៉ុលពត” ថា “មិនមានប៉ុលពតទេ” ទៅដល់អាថៃបកវាៗដើរពីក្រោយយើងម្នាក់មួយៗថា “ចេះខ្មែរ” ជនជាតិគេនៅចេះខ្មែរ

ច្រើននៅគេដើរពីក្រោយយើង គេនិយាយថាទាហានគេនិយាយមក គេបកប្រាប់មកយើង គេបញ្ជូនយើងទៅហើយ ឲ្យទៅស្រុកខ្មែរវិញ គេមិនទទួលទេ ថាវិលទៅវិញ។ យើងក៏ មកតាមគេមក តែប្អូនឯងកុំភ័យកុំរត់ទោះបីវាវ៉ៃយ៉ាងណាកុំរត់ៗងាប់ហើយ។ ចឹងបានទទួលបញ្ជាថាគេបាញ់ចោលៗយកម្នាក់ទៅ បាញ់មែន មិនមែនបាញ់ចោលទេ បាញ់មែន គេបាញ់ទៅលើ បាញ់បង្អើលយើង គេប្រាប់ថាព្រួសូរកាំភ្លើងក៏កុំផ្អើល បើគេថាបាញ់ចោលមែន កុំផ្អើលបាញ់មែនហើយទៅមែនទៅមុនម្នាក់នៅ២នាក់នឹង បានបញ្ជូនទៅ ស្រុក នឹងគេបញ្ជូនទៅនោះ ទៅផ្លូវផ្សេង។

ប៊ុនថន : បែកគ្នា?

វើយ : អត់ទេ អត់បែកទេ។

ប៊ុនថន : អ្នកមុន?

វើយ : យកទៅម្នាក់ចឹង គេបាញ់រួច គេបញ្ជូន ខ្ញុំនឹងមួយទៀត យកយើងទៅមួយទៀត បាញ់ចោលទៀត។ មកដល់គេប្រាប់ឯងថា "អានោះរត់បាត់ហើយ រត់ទៅស្រុកខ្មែរវិញ ឯងទៅតាមគ្នាឯងទៅ បើមិនទៅទេថៃបាញ់ចោល" ចឹងយកយើងទៅទៀតហើយ ប៉ុន យើងជឿថាថៃបកពីក្រោយទៅថាកុំផ្អើល ទៅដល់បាញ់ទៀតដុងៗ យកទៅណាបាត់អត់មកឲ្យយើងឃើញទេ យើងក៏មិនបានឃើញគ្នា ឈប់ឃើញហើយ វាចងមុខរៀងខ្លួន។ ចឹងទាល់តែយើងទៅក្រោយទៀតដល់ទៅនោះ គ្នាឯងស្លាប់អស់ហើយ ទៅវិញ។ ហើយ យើងមិនទៅក្រោយឈប់បាញ់ វ៉ៃរុញយ៉ាងណាយើងមិនទៅ ថានេះបកភាសានៅពីក្រោយយើងកាន់ខ្សែជាប់។ នាំទៅៗក៏ឡើងឡាន យើងមិនដឹងថានៅត្រង់ណាដងកាត់ដុបកាត់ព្រៃទៅឡើងឡានៗទៅនៅតាប់ផ្សា។

ប៊ុនថន : តាប់ផ្សានៅដីថៃ?

វើយ : ថៃ។ ខ្លះគេកន្លែងគុសៗ កន្លែងឃុំគេ កន្លែង.....បើខ្មែរយើងថាឃុំ។ ចឹងយើងទៅចូលនៅគុកគេទៅ គេដឹកយកទៅនឹងចូលដល់កន្លែងគុក។ គេក៏ចាប់ផ្តើមបើកមុខយើងចេញ បើកទៅក៏សុទ្ធតែខ្មែរ អ្នករត់មកក៏រត់បន្តគ្នា ហើយគេសួរយើងថា "ភ័យអត់" "និយាយមិនភ័យម៉េច ភ័យ" "ចុះម៉េចមិនរត់ទៅខ្មែរវិញ?" "ចុះខ្ញុំមកពីខ្មែរ ខ្ញុំរត់ទៅលើវិញចប់"។ ចឹងក៏គេឲ្យយើងមានសេរីភាព មិនមានសេរីភាពប៉ុន្មានទេ បាយគេមានកំណត់ឲ្យស៊ីថៃ។

ប៊ុនថន : កំណត់យ៉ាងម៉េច?

វើយ ៖ កំណត់ក្នុងម្នាក់បាយបានតែត្រឹមម៉ាវែកយើងនេះ វែកគ្រលោមធំយើងនេះ បាយសម្រាប់ម៉ាវែកទេ ម្ហូបម៉ាវែកដាក់ស្រូបជាមួយគ្នាឲ្យយើងស៊ី ថាសឹងថាហេតុអីបានគេថាចឹង ។ ដែលគេឲ្យៗយើងស៊ីនឹង គេថាខ្លាចលរយើងដាច់ពោះយូរហើយ ស៊ីទៅវាខូចក្រពះចឹងវាឲ្យយើងស៊ីនឹងឲ្យក្រពះយើងវាខាន ហើយក្រពះខាននឹងវារីកតិចៗ បើសិនឲ្យយើងស៊ីតាមយើងឃ្លានស្លាប់ វាថាស្លាប់ៗប្រហែលជាស្លាប់មែន ចុះឃ្លាន ដូចខ្ញុំថាឆ្នាំងប៉ុននេះគ្នា ២-៣នាក់ កូនឯងកើតប៉ុននេះហូបអស់ ធ្វើម៉េចបានអស់ ។ ចុះម៉េចអាពួកដាច់ពោះនឹងវា៣នាក់នឹងវាហូបមិនគ្រប់ ចឹងយើងហូបច្រើនទៅវារីកក្រពះ ធ្លុលក្រពះ ។

ប៊ុនថន ៖ ចឹងអ៊ំនៅនឹងជាប់យូរទេ?

វើយ ៖ អា៣ខែៗបានគេបញ្ចេញមកស្រុកវិញ បញ្ចេញមកទាហានៗគេដើរ គេនៅមិនទុកចិត្តទេ ថាខ្ញុំនឹងជាទាហានថៃ អឺ!ទាហាន ។

ប៊ុនថន ៖ ខ្មែរក្រហម?

វើយ ៖ ខ្មែរក្រហម ។ ចឹងឲ្យខ្ញុំមកនៅតាមជាយដែន នៅជុំទាហានថៃនឹង នៅមកឲ្យគេស៊ីៗនឹងគេទៅ បានម៉ាអាទិត្យឃើញមកយកខ្ញុំទៅវិញ ដឹងទៅជាយអារញ្ញនោះ ។

ប៊ុនថន ៖ បាទ! ទៅខេត្តអារញ្ញ?

វើយ ៖ បាទ! ទៅកន្លែងស៊្វូ គេហៅស៊្វូ ។

ប៊ុនថន ៖ ជំរំ?

វើយ ៖ ជំរំៗខ្មែរនោះ លុះគ្រាតែនៅគាប់ផ្សានេះជាប់បានពេញម៉ាក្នុង... ហើយអង្គការសហប្រជាជាតិមកសម្ភាសន៍ៗ គេដឹកទៅម៉ាសារ ដឹកយកទៅចោលអារញ្ញ ។ កន្លែងអារញ្ញកន្លែងធំ កន្លែងផ្ទះ កន្លែងសំណាក់ កន្លែងស្មីគេ អង្គការវាធំៗ បើគាប់ផ្សានេះ គ្រាន់ថាគេមកសម្ភាសន៍ម្តងម្កាល ។ ពេលដែលថាមានអ្នករត់ចូលថ្មីចេះ គេមកសម្ភាសន៍ បើមិនមានទេ មកតែពួកអង្គការកាកបាទក្រហម ដែលបាយទឹកនឹងវាមករាល់ថ្ងៃ ប៉ុនវាមកសម្រាប់តែបាយទឹកទេ ។ តែបាយទឹកគេមានកំណត់ អត់មានឲ្យស៊ីតាមការនឹកឃើញរបស់យើងទេ ល្ងាចឡើងចឹងមានពេលគេឲ្យដេកជាប់ៗគ្នាចេះទៅ ដេកសុទ្ធតែផ្អៀងចេះ ។

ប៊ុនថន ៖ អត់មានកន្លែងដេកទេ?

វើយ ៖ ចុះវាច្រើន មានអីកន្លែងដេកក្រោមសាលាស្រុកនេះ ។

ប៊ុនថន ៖ ច្រើននាក់ដែរ រាប់ពាន់នាក់?

វើយ ៖ កន្លែងនោះកន្លែងសាលាស្រុក ជាង១០០នាក់ ចូល២០០នាក់នោះ ទាល់តែពេញៗ ហើយគេសម្ភាសន៍ៗដឹកបណ្តើរៗ ដឹកទៅសួនអារញ្ញ បើទៅដល់អារញ្ញកន្លែងជំរំធំនឹង ហើយ ដឹងថាសេរីភាពហើយ អត់មានអីទេ។

ប៊ុនថន ៖ ចឹងពូបានទៅនៅនឹង?

វើយ ៖ បាទ! នៅ ដល់នឹងនេះគេធ្វើបាបរៀងរាល់ល្ងាចៗ

ប៊ុនថន ៖ ធ្វើបាបយ៉ាងម៉េច?

វើយ ៖ អ៊ំបានថាស៊ីចុកអី យើងឈរតំរង់ជួរមិនត្រឹមត្រូវ គេទាត់គេវ៉ៃ ហើយល្ងាចឡើងឲ្យដេកចេះ និយាយគ្នាឲ្យឮនឹង មកជាន់ មកវ៉ៃ គេរាប់គេវ៉ៃៗ ប៉ុនបើតាមមែនទែន វាមិនមែនមកធ្វើអី ប៉ុនបើស្រ្តីច្រើនៗ វាដូចថាចង់រំលោភក្មេង ថានាំប្រពន្ធរត់ផង មានស្រ្តីទៅផង ពិបាកការពារតែស្រ្តីៗ

ប៊ុនថន ៖ ប៉ុន្តែមានទេ?

វើយ ៖ មានតើ មានស្រីរត់ទៅដែរ តែយើងពិបាកការពារ ចុះអំណាចនៅលើគេ ចុះស្រ្តីរត់ទៅចេះទៅ យើងមិនចង់ឲ្យគេយកទៅធ្វើបាបទៅរំលោភណា៎ ចុះម្នាក់ៗកាន់ទុក យកវ៉ៃឯងធ្វើបាបឯងចឹងៗ

ប៊ុនថន ៖ ប៉ុនមានអ្នកដែលថាយកទៅរំលោភទេ?

វើយ ៖ អឺ!មិនសំរាំងថាមានមិនមានទេ ប៉ុនថាវាមកចង់ទាញអូសដៃ យើងអត់ឲ្យយើងជាប្រុសៗមិនឲ្យទេ យកឈ្នះៗ ម៉ារន្ធង់ត្រង់នេះ ខ្ញុំដេកជិតចេះ បើសិនណាយើងការពារទាំងអស់គ្នាអត់ឲ្យទៅៗ

ប៊ុនថន ៖ ប៉ុន្តែមានអ្នកយកទៅបានទេ?

វើយ ៖ អត់បាន មិនដឹងយ៉ាងណាៗ

ប៊ុនថន ៖ ពេលពូអំឡុងពេលពូនៅអត់យកទៅបាន?

វើយ ៖ បាទ! អំឡុងដែលខ្ញុំយកទៅនៅនឹងមិនបានយកទៅបានទេៗ

ប៊ុនថន ៖ យកតែមនុស្សចាស់ ចង់យកតែក្មេងៗ ឬមនុស្សចាស់?

វើយ ៖ អ៊ើ! ចាស់ដែលរត់ទៅអីវាស្រីៗ បានតែក្រមុំ ត្រឹមវ័យកណ្តាលកូនមួយ ដែលរត់ទៅនៅនោះកូនមួយ យកទៅ ប៉ុនកូនមួយវាអត់ដឹងថាក្មេងចាស់អី អារឿងវាចង់រំលោភៗ ប៉ុន្តែ ម៉ាចំណោមដែលខ្ញុំទៅនឹង រយៈពេល៣ខែអត់មានទេ ជាប់នៅនឹង៣ខែៗបានគេបញ្ជូនទៅ អារញ្ញសេរីភាពៗ អង្គការសហប្រជាជាតិទទួលស្គាល់ពេញសិទ្ធិៗ

ប៊ុនថន : ចុះពីមុនមកមានរំលោភមានអី ពីមុនពូ ឬក្រោយពូទេអីទៀតទេ?

វើយ : ទេ! អានឹងគ្រាន់ថាដូចគ្នា មិនដឹងជាវារំលោភបាន ឬក៏អត់ ក៏ប៉ុនគ្រាន់ថាក្នុងចំណោម ដូចថាដេកម៉ាកន្លែងឃើញយើងមកអូសទាញ ក៏យើងមិនឲ្យ ប្រទាញប្រទុងគ្នាមិនឲ្យ មិនដឹងជាវាយកបាន ឬមិនបាន អត់ដឹងទេ នេះថៃ។

ប៊ុនថន : ចុះជាប់នឹងមានដាក់ មានឈ្មោះមានអី?

វើយ : អត់ទេៗ ប៉ុន្តែគ្រាន់ថាសេរីភាពយើងមិនអាចដើរបាន។ ថាអានេះជាទីសាលាស្រុកដែលគេត្រូវដាក់យើងរង្គង់ដែលយើងត្រូវដេកនៅអានេះ ហើយរបងឯងនោះព័ទ្ធជុំវិញសុទ្ធតែរបងលួស បើយើងមានសេរីភាព មានទន្ទឹមថាដើរពីត្រង់នេះទៅត្រង់នោះបាយៗ តែហួសព្រំដែននឹងអត់បាន ចង់ទៅទិញអីស៊ីអត់បាន។ ហើយបើអ្នកខ្មែរដែរនៅថៃនោះ អាខ្មែរ-ថៃ ខ្មែរពីជំនាន់ដើមដែលថៃយកទៅគ្រប់គ្រងចង់មកលេងខ្មែរ ចង់មកសួរសុខទុក្ខខ្មែរទាល់តែមានច្បាប់ពីថៃ។ ហើយមកបានឈរទទេរ ឈរម្ខាងតំបន់ម្នាក់ ម៉េចប្អូនឯងនៅណាភូមិណា ស្គាល់បងប្អូនខ្ញុំទេ ចុះវាបងប្អូនវាពូវាត្រង់នេះ នៅចេះភូមិនោះៗ។ បើយើងស្គាល់បងប្អូនធូរ ហើយម៉េចបានថាធូរ ឧបមាថាអូ!ខ្ញុំស្គាល់ឈ្មោះនោះៗខ្ញុំស្គាល់ ចឹងគាត់នឹងអាចមានទំនាក់ទំនង ស្អែកឡើងមានបាយមានម្ហូប បានប្រាក់យកសម្រាប់ឲ្យយើងហូបក្រៅ បើកប្រាក់ចាយ។ បើឧបមាថាយើង វាយកបាយយកមកចង់ជួបឈ្មោះអី សរសេរឈ្មោះមក ប្រាប់អាអ្នកខាងក្នុងខ្មែរយើងដែលនៅក្នុងបកគេដើររកយើងយកទៅជួប។ ដល់ទៅជួបទៅ គេឲ្យនំ បាយ ប្រាក់ដែលយើងស្គាល់អានេះជាបងប្អូន។

ប៊ុនថន : ចឹងពូទៅនៅជំរំ ទៅនៅអារញ្ញ បានរយៈពេលប៉ុន្មាន?

វើយ : អារញ្ញទៅនៅប៉ុន្មានខែ មិនបានជាចំណាំ ក្នុងនោះគេបញ្ជូនខ្ញុំ ហ៎!មិនជាបញ្ជូនទេ គេឲ្យខ្ញុំវិលមកវិញ វិលដោយចិត្តឯង ចង់មកធ្វើខ្មែរសៗនេះទាហានក្មេងតស៊ូជាមួយខ្មែរក្រហម ចឹងរត់ចេញពីសួនអារញ្ញមកវិញ គ្មានបានទៅក្រៅនឹងគេទេ គឺរត់ចេញ។

ប៊ុនថន : ទៅខ្មែរ-សនឹង ជាមួយពីណាវិញ?

វើយ : មកជាមួយលោកនែក! តាលួត សឺន សាន ទាហានខាងសឺនសាន។

ប៊ុនថន : ខាងប៉ារ៉ា?

វើយ : បាទ!ខាងប៉ារ៉ា នឹងខ្មែរសនឹងឯង ពួកខ្មែរស ពួកសឺនសាន ប៉ារ៉ា មិនទាន់កើតចេញពេញសិទ្ធិទេ ក៏រត់ៗចេញពីសួនមកដោយខ្លួនឯង អត់មានគេបញ្ជូនយើងអីទេណា។ លួចចេញមកវិញ លួចចេញពីកន្លែងនោះមកតាមរយៈបងប្អូនខ្លួនឯងថា ហ៎!គេធ្លាប់ធ្វើប៉ារ៉ា ខ្មែរ-

សអានេះច្រើនហើយ អញក៏ប្រឆាំងជាមួយខ្មែរក្រហមដែរ មកវិញ ។ បង្អត់បាយ បង្អត់ទឹកអញ ៗមកវិញ មកប្រឆាំងធ្វើទាហានវិញ ។ ដល់មកក៏នៅជាមួយខាងទាហានសឹនសាននឹងទៅ រហូតដល់ទីបញ្ចប់បានបែកបាក់ឆ្នាំ៧៩ ដែលបែកបាក់ខ្មែរបែកបាក់ហើយ មិនទាន់ នេះទេ មិនទាន់យកជ័យជំនះណាណែទេ ប្រទាញប្រទុងគ្នា ។ ខ្មែរក្រហមក៏មានយួនក៏រុញ មកពីនោះ ខ្មែរក្រហមក៏នៅតាមជាយដែន អាពួកប៉ាវ៉ា សឹនសានក៏ចុះឡើងមកវិញទាល់ គ្នា ។ ពួកនឹងដូចគេហៅថា ឆ្កែ និង ឆ្មា ។

ប៊ុនថន : យ៉ាងម៉េចវិញ?

វើយ : ម៉េចបានថាឆ្កែ និង ឆ្មា ខាងទាហានសឹនសាន ចុះមកឃើញយួន បាញ់យួន ទាហានយួនឃើញប៉ាវ៉ានឹងបាញ់ប៉ាវ៉ាទៅ ហ៎! ទៅជួបខ្មែរក្រហមបាញ់ខ្មែរក្រហម ៗជួបយើង ប៉ាវ៉ាបាញ់ប៉ាវ៉ា ជួបយួនបាញ់យួន ។ ចឹងអាពួកអស់នោះមិនដឹងជាយ៉ាងម៉េច វាប្រទាញប្រទុងគ្នាដូចឆ្កែហើយនឹងឆ្មា ជួបមុខអាណាក៏បាញ់ ។ គេបាញ់យើង ៗបាញ់គេ ជាមួយគ្នាឯង ដូចថាប៉ាវ៉ាដូចគ្នា សំគាល់សញ្ញានៅលើមួកហើយនឹងសំលៀកបំពាក់តែប៉ុននោះ បើសំលៀកបំពាក់អាចក្លែងក្លាយបាន បើសញ្ញាមួកមិនអាចក្លែងក្លាយបាន តែឃើញលើកមួកប្រឹប អូ! គ្នាឯង មិនបាច់ធ្វើទេអានឹង ។ បើថាមកអាពេល.......ខ្មែរក្រហមឃើញ......ហើយខ្មែរក្រហមគេថា គេតស៊ូជាមួយយួន ៗដេញគេចូលដុបចូលព្រៃ គេប្រឆាំងជាមួយយួន ចឹងអាពួកប៉ាវ៉ានេះក៏ថា អាខ្មែរក្រហមដេញអញបានអញមកនៅក្នុងប្រទេសថៃ ចឹងអាខ្មែរក្រហមនឹងបង្អត់បាយអញទាំងអស់ មិនដឹងអាណាខុស អាណាត្រូវកាំភ្លើង ។

ប៊ុនថន : ចឹងពូមកនៅខាងណាវិញ?

វើយ : នៅខាងទាហានសឹន សាន ។

ប៊ុនថន : បាទ! នៅម្តុំណាវិញ?

វើយ : នៅម្តុំយើងបឹងត្រកួន ។

ប៊ុនថន : អានឹងពូមកនៅជាមួយពីណា មេ?

វើយ : មេអី! លោកតាលួត ។

ប៊ុនថន : នឹងគាត់កាន់ៗ?

វើយ : គាត់កាន់ជំរំ ហើយលោកតាសឹនសានៗប្រធានទាក់ទងជុំវិញក្នុងយកជំនួយមកជួយ បើមេបញ្ជាការនឹង គឺថាមានខាងបន្ទាប់បន្សំ មានលោកតាលួត ហើយមេបញ្ជាការដែរធំមាន លោកអី! ជឿម ដែល ។

ប៊ុនថន ៖ ដៀម ដែល?

វើយ ៖ បាទ!

ប៊ុនថន ៖ លោកតាលួនហ្នឹងគាត់នៅរស់ដែរ?

វើយ ៖ ស្លាប់អស់ហើយ ។ នៅតែលោកតាខិន ដែលទេ នៅសព្វថ្ងៃមិនដឹងជានៅកន្លែងណា ឬចំនុចណា ។

ប៊ុនថន ៖ ពូកូនទាហាន?

វើយ ៖ ខ្ញុំកូនទាហានទេ ។

ប៊ុនថន ៖ ឬក៏មានកាន់ក្រុមកាន់អីដែរ?

វើយ ៖ បាទ! មិនបានអីទេ កូនទាហានចល័តទាំងអស់គ្នា ដើរធ្វើការ ប៉ុន្តែគ្រាន់តែចិត្តរៀងៗខ្លួន គេក៏ចិត្ត យើងក៏ចិត្តទៅកូនទាហាននឹង ។

ប៊ុនថន ៖ ចុះបងប្អូនពូមានរត់ទៅនឹងដែរទេ?

វើយ ៖ អត់មានទេ ។

ប៊ុនថន ៖ បងប្អូនពូនៅ?

វើយ ៖ អត់មានទេ នៅនេះទាំងអស់ ។

ប៊ុនថន ៖ ឪពុកម្តាយ?

វើយ ៖ ឪពុកម្តាយស្លាប់តាំងពីមុនសម័យ៣ឆ្នាំ ។

ប៊ុនថន ៖ ចុះពេលពូរត់ទៅបងប្អូនគេអត់ធ្វើអីដែរ?

វើយ ៖ នែក! អត់ធ្វើអីទេ តែប្រពន្ធខ្ញុំគេត្រូវបានបញ្ជូនទៅដល់ថ្នល់ដាច់ៗបានជួបពួកអាប៉ាវ៉ា យើងនេះចុះមក ជួបប៉ាវ៉ាចុះមកសម្លាប់មកកើតបញ្ជូនមកវិញ ។ អានឹងប្រទាញប្រទុងដូចខ្ញុំថាចឹង ។

ប៊ុនថន ៖ ប៉ុនពូមានគ្រួសារពេលណា ឆ្នាំប៉ុន្មាន?

វើយ ៖ ខ្ញុំមានគ្រួសារឆ្នាំ៧៤ ។

ប៊ុនថន ៖ អូ! មានមុនៗ តាំងពីមុន?

វើយ ៖ មុន ប៉ុនខ្ញុំគេចេះតែឲ្យដើរចល័ត ដែលខ្ញុំដើរចល័តនឹងមិនមែនខ្ញុំកម្លោះទេ គឺខ្ញុំអ្នកចាស់មានកូនមួយទៅហើយ ។

ប៊ុនថន ៖ ចឹងប្រពន្ធពូអត់នើយ ខ្មែរក្រហមគេអត់ធ្វើបាបអីដែរ?

វើយ ៖ អត់ទេ អត់ដែរ ខ្ញុំរត់ទៅដុតគេក៏មិនគៀបសង្កត់ម៉េចទេ ប៉ុនដល់ក្រោយមកគេប្រុង ជម្លៀសចោលដែរ តែទៅវាមិនកើត ពួកប្រទាញប្រទុងវាច្រើន យួនឯងនេះក៏ដេញ អា ពួកប៉ុរ៉ាំនេះក៏ដេញត្រឡប់មកវិញ អាខ្មែរក្រហមនេះវាឆ្លេឆ្លាៗដូចអានេះការសម្ងាប់ចឹង ព្រោះអាយួននោះវាឡើងមកបុកដល់នេះ ហើយអានេះវារត់ទៅដល់ព្រំដែនទៅដល់ប៉ះអា ទាហានប៉ុរ៉ាំ គ្មានស្គាល់អាណាទេ ដូចខ្ញុំថាថ្ងៃ និង ឆ្នាំចឹង ។ អាប៉ុរ៉ាំឃើញខ្មែរក្រហមក៏ បាញ់ខ្មែរក្រហម ឃើញអាទាហានយួន ទាហានខ្មែរ ក៏បាញ់អាទាហានយួននេះទៀត បាញ់ទាំងអស់ ។ អាខ្មែរក្រហមនឹង បាញ់ទៅវិញទៅមកទាំងអស់គ្នា រកកសិណមិនឃើញ ពួកអស់នេះ ។

ប៉ុនថន ៖ ចឹងបញ្ជាការធំ ពូនៅបឹងត្រកួន?

វើយ ៖ បាទ! នៅបឹងត្រកួន មានឯកឧត្តមសឺន សាន គេបញ្ជាការទាក់ទាញស្បៀងអាហារ បាន គេហៅថាទាហានសឺនសានៗគេនឹងឯង ។ ហើយមេបញ្ជាការបន្ទាប់មកមានលោកតាជឿម ដែល ហើយក្រោយមកក្រោមៗមកទៀត គេមានលោកតាម៉ាំង ហើយវាមានលោកតែ នេះខ្ញុំនិយាយមិញច្រើននាក់ដែរខាងក្រោមៗ ដែលធំៗមានតែបន្ទាប់ៗ គ្នាឲ្យរៀបចំនៅ ទីកន្លែងនេះទៅ ។ ចឹងខ្ញុំក៏បានមកដល់ សំណាងខ្មែរក្រហមចូលមក៧៩ៗ វៀតណាមចូល ដល់ ខ្ញុំវិលមកស្រុកវិញ បានឃើញប្រពន្ធកូនខ្ញុំរស់មែនៗ ខ្ញុំក៏វិលទៅធ្វើទាហានវិញទៅ កូនៗមានអីអត់ទៅតាមខ្ញុំទៅរស់នៅស្រុក ហើយខ្ញុំក៏ទៅតែឯងទៅធ្វើទាហានទៀតទៅ ។

ប៉ុនថន ៖ ចុះនៅបឹងត្រកួននឹង ខ្មែរក្រហមពីពួកនេះចេញអស់?

វើយ ៖ ខ្មែរក្រហមមិនមានគោលដៅទេ គេចេញបែកគេទៅនៅតាមម៉ាចង្កោមៗវាទៅ អានេះទៅ នៅចង្កោមនេះទៅ ។

ប៉ុនថន ៖ ចុះពួកនេះអ្នកណាគ្រប់គ្រង ថ្នពួកនេះ?

វើយ ៖ នេះអីរកទើបរកអ្នកគ្រប់គ្រងអត់ឃើញ ។

ប៉ុនថន ៖ ខាងកងទ័ពវៀតណាម?

វើយ ៖ បាទ! កងទ័ពវៀតណាមមកបានម៉ាកំណាត់ចេះមក ។

ប៉ុនថន ៖ ហើយខាងប៉ុរ៉ាំ?

វើយ ៖ ប៉ុរ៉ាំម៉ាកំណាត់មក ចឹងបានខ្ញុំថាតែជួបមុខអាណាៗក៏បាញ់ដែរ ពួកនឹងដូចជាថ្ងៃ ហើយ នឹងឆ្នាំ វាតែឃើញគ្នាអាណាក៏ខាំមិនដឹងជាយ៉ាងម៉េច ។

ប៉ុនថន ៖ ទីតាំង ទីរួមស្រុកនេះ អត់មានខាងណាឈរជើង?

រើយ ៖ មិនមានឈើរដើងទេ រហូតដល់មកចុងក្រោយបានខាងរដ្ឋកម្ពុជានឹង គឺគាត់បានមកឈើរដើង ហើយឈើរដើងនឹងខ្មែរក្រហមនៅផ្នែកផ្សេងទៅ ប៉ុន្តែយើងនៅផ្នែកផ្សេងទៅ ។ តែឡើងវិញរហូតមកដល់នេះ ។

ប៊ុនថន ៖ បាទ! ពូឡើងវិញចូលដល់នឹងដែរ?

រើយ ៖ ខ្ញុំមិនដែលបានមកវិញនឹងគេទេ ខ្ញុំធ្វើទាហាននឹងគេដែរ តែមិនដែលបានមកស្គាល់ជាតិការវ៉ៃដំប្រំធាក់នឹងគេ ។

ប៊ុនថន ៖ វ៉ៃជាមួយខាងវៀតណាម?

រើយ ៖ ខាងណាក៏មិនដែលបានវ៉ៃ នៅតែក្នុងនោះ ។ ធ្វើការងារខាងក្នុង ការិយាល័យ ។

ប៊ុនថន ៖ ការងារអីខ្លះ?

រើយ ៖ អឺ! ខាងស្បៀងអាហារក-៨ ខាងសិក្សា ឧបមាថាអ្នកណាត្រូវជាមេកង ឬមេក្រុមចង់ទៅរៀន យកទៅកន្លែងខ្ញុំ ។

ប៊ុនថន ៖ រៀនអីវិញ?

រើយ ៖ រៀនខាងក្បួនប្រយុទ្ធ ក្បួនទាហាន ក្បួនប្រយុទ្ធ យុត្តិសាស្ត្រនៃការប្រយុទ្ធ ចឹងរបៀបយើងធ្វើសង្គ្រាម យើងធ្វើរបៀបម៉េចៗមានជ័យជំនះលើគេ ។ យើងរៀនរបៀបម៉េចដើម្បីរស់ខ្លួនឯង ហើយវ៉ៃបន្ទាយមួយត្រូវស៊ើបការណ៍យ៉ាងណា ចូលយ៉ាងណាបានយកជ័យជំនះលើបន្ទាយនេះបាន ។ ចឹងខ្ញុំនៅខាងផ្នែករបស់គេ គ្មានបានការណ៍អីទេ ខ្ញុំមិនដែលបានចេញមកចំមកជួបកងទ័ពណាបាញ់គ្នា ។

ប៊ុនថន ៖ ពូនៅឆ្នាំប៉ុន្មានបានពូចូលមកនៅ?

រើយ ៖ ខ្ញុំនៅឆ្នាំ អឺ!អ៊ុនគាត់ចូលមកឆ្នាំប៉ុន្មានទេ ខ្ញុំភ្លេចបាត់ហើយ ។

ប៊ុនថន ៖ ៩១?

រើយ ៖ ៩៣ៗខ្ញុំបានចូលមកភូមិវិញ ។ ហើយចូលមកដល់ខ្ញុំក៏នៅបាត់ដំបង មិនទាន់បានចូលភូមិទេ អ៊ុនគាត់មកនៅគ្រប់គ្រងទាំងអស់ ចឹងខ្មែរក្រហមក៏ហៅបញ្ចូល ប៉ុន្តែក៏ហៅបញ្ចូលទាហានខ្មែរក៏ហៅបញ្ចូល មកនៅគោករមៀត បឹងត្រកួននេះក៏ហៅបញ្ចូលគ្នា ។ រួចបានខ្ញុំគេដកយកទៅនៅបាត់ដំបង៤ឆ្នាំ ។

ប៊ុនថន ៖ ពូនៅជាកងទ័ពដដែល?

រើយ ៖ នៅជាទ័ពដដែល នៅជាគ្រូបង្រៀនខាងយុត្តិសាស្ត្រ នៅ៤ឆ្នាំ ខ្ញុំក្នុងការរស់នៅនឹងដូចថាលុយខែពិបាកក្នុងការចិញ្ចឹមកូនប្រពន្ធ ខ្ញុំក៏វិលមកវិញ សុខចិត្តមកធ្វើស្រែ ។

ប៊ុនថន : ធ្វើស្រែ រាល់ថ្ងៃនេះពូធ្វើអី?

វើយ : ធ្វើតែស្រែ ។

ប៊ុនថន : ហើយកូនប៉ុន្មាននាក់?

វើយ : កូន៣ ។

ប៊ុនថន : ប៉ុនធំៗអស់ បានរៀនសូត្រទេ?

វើយ : កូនបានធ្វើការងារ បានរៀនរួចខ្លួនមួយ ។ បើកូនមួយ ពៅៗលីវ មិនទាន់មានគ្រួសារទេ បើកូនប្រុសទី២នេះ បានមិនទាន់មានគ្រួសារដែរ តែគេសិក្សារួចខ្លួនរបស់គេ បានគ្រូបង្រៀនពេញសិទ្ធិលក្ខណៈរបស់រដ្ឋយើង ទៅសិក្សានោះ២ឆ្នាំចប់មកបង្រៀននេះបានម៉ាឆ្នាំ កូនខ្ញុំក៏ឈប់នៅនេះទៅ គេក៏ចូលក្រុមហ៊ុន ឈប់ធ្វើគ្រូបង្រៀន លះបង់គ្រូបង្រៀន គេចូលធ្វើការក្រុមហ៊ុនបារីសេកនៅបាន៤-៥ឆ្នាំ ។ សព្វថ្ងៃនៅប៉ៃលិន ។

ប៊ុនថន : ចឹងពូនៅនេះស្គាល់តាពិនអីទេ?

វើយ : បាទ!

ប៊ុនថន : តាពិនឌុប ប្រធានគុកទួលស្លែង គាត់នៅផ្គាំ?

វើយ : អូ! មិនស្គាល់ទេ ។

ប៊ុនថន : អត់ដែលស្គាល់?

វើយ : បាទ! មិនស្គាល់ទេ តាឌុបនឹងមិនដែលស្គាល់ ឮតែគេហៅ ឮតាមវិទ្យុ ឮតាមអីទេ ថាឲ្យស្គាល់តាំងពីតូចរៀងមក ចាស់ដូចគ្នាមែនប៉ុនមិនស្គាល់ ។ ទេ! តាពិន ស្រុកកំណើតនៅផ្គាំដូច ខ្ញុំមិន ។

ប៊ុនថន : គាត់ទៅរស់នៅផ្គាំ ស្រុកកំណើតគាត់នៅកំពង់ធំ ។

វើយ : អូ! គាត់ទៅមករស់នៅផ្គាំ ចឹងបានថាជម្លៀសកាលណាមកពីភូមិមួយទៅភូមិមួយមិនអាចស្គាល់បានទេ ភូមិជិតគ្នាមែន តែភូមិមួយទៅភូមិមួយមិនអាចស្គាល់គ្នាបាន គឺអាពួកសម័យនឹងវាដូចថាមិនឲ្យស្គាល់ ។ បើស្គាល់ប្រធានភូមិភាគអី សម័យនោះប្រធានសភូមិភាគអីបេះសម្គាល់ឲ្យខ្លះ ហើយយើងភ្លេចឈ្មោះខ្លះ ។

ប៊ុនថន : ហើយចឹងខ្ញុំអត់មានសួរអីលោកពូទៀតទេ អស់សំនួរហើយលោកពូមានអីចង់ថែមទៀតទេ?

វើយ : បាទ! អត់មានអីចង់បន្ថែមទេ តែបើថានៅក្នុងនឹង ដូចថាក្នុងរបៀបរបបនៃសង្គម៣ឆ្នាំ ៨ ខែ ២០ថ្ងៃហ្នឹង ដែលអាចផ្តាំផ្ញើ ឬក៏ផ្នែកអគ្គការណាមួយ ដូចថាធ្វើយ៉ាងណាទប់

ស្កាត់ ដើម្បីកុំឲ្យអំពើ និងរបបហ្នឹង កើតឡើងបន្តទៀត ធ្វើយ៉ាងណាសុំកុំឲ្យមាន សុំកុំឲ្យមានដូច ថាគ្រប់ផ្នែកអង្គការទាំងអស់គឺថាជួយស្តុបកុំឲ្យមានរបបនឹងបន្តទៅទៀត។ ទោះបីសង្គមណា ក្រោយៗទៀតកុំឲ្យគ្នាស្គាល់ជាតិ។ បាទ!ស្គាល់ត្រឹមខ្ញុំបាទមុនប៉ុននេះបានហើយ ក្រោយទៀត កុំឲ្យមានស្គាល់សង្គមរបៀបនោះទៀត សង្គមប្រជាធិបតេយ្យនឹងវាដូចជាព្រៃផ្សៃ មិនអាចឲ្យកូនចៅខាងក្រោយស្គាល់បានទេ គឺវាវេទនាហួស ជួយទប់ស្កាត់តែប៉ុននោះទេ។

ប៊ុនថន ៖ ចឹងខ្ញុំអរគុណលោកពូច្រើន។

«ចប់»